# ពុទ្ធប្បវត្តិ

# សន្តិកេនិទាន

## ភាគ ៣

ផ្ទះលេខ១៣៦អឺ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស.២៥៤៦ គ.ស.២០០២

ខ្ចីដោយពីលោកឡុង ឃុនសំរ៉េង ក្រុមការងារ ដើម្បីផ្តក
តំកល់ក្នុង elibrary of Cambodia កក្កដា 2015

## ពុទ្ធប្បវត្តិ

# សន្តិកេនិទាន

## ភាគ ៣

ផ្ទះលេខ១៣៦អឹ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស.២៥៤៦ គ.ស.២០០២

# អារម្ភកថា

សៀវភៅ « ពុទ្ធប្បវត្តិសន្តិកេនិទានបច្ឆិមពោធិកាល » នេះ ខ្ញុំបានដកស្រង់អំពីមហាបរិនិព្វានសូត្រខ្លះ អំពីគម្ពីរបឋមសម្ពោធិខ្លះ មករចនារៀបចំតាមលំដាប់នៃរយៈកាលដែលព្រះបរមសាស្តាយាងប្រោសសត្វតាមស្រុកនិគមជនបទ ដរាបដល់បរិនិព្វាន ព្រមទាំងអបរកាល គឺកាលខាងក្រោយបរិនិព្វាន មានសំដែងអំពីរបៀបបូជាព្រះពុទ្ធសរីរៈ និងការចែកព្រះសារីរិកធាតុ ដំកល់ទុកជាច្បាប់សម្រាប់ឧបត្ថម្ភការសិក្សាធម្មវិន័យ ថ្នាក់ត្រី-ទោ ។

ក្នុងការរៀបរៀងនេះ ខ្ញុំសូមអភ័យទោសអំពីសំណាក់អ្នកប្រាជ្ញទាំងឡាយក្រែងមានភ្លាំងភ្លាត់សេចក្ដីត្រង់ណា មេត្តាកែតម្រង់ឲ្យបានផង ។

សៀវភៅច្បាប់នេះ ខ្ញុំបានប្រគល់ឲ្យបណ្ណាគារ ជិន - ង្វួន - ហួត បោះពុម្ពផ្សាយតទៅ ។

សូមព្រះពុទ្ធសាសនា ចំរើនរុងរឿង អស់កាលជាអង្វែងទៅហោង ។

ថ្ងៃអង្គារ ៧ កើតខែអាសាឍ ឆ្នាំមមែសប្តស័ក. ព.ស. ២៤៩៨

អតីតសិស្សសាលាបាលីជាន់ខ្ពស់

**ខ្លួត - ធីម**

# នមត្ថុ រតនត្តយស្ស

## ពុទ្ធប្បវត្តិ

### សន្តិកេនិទាន

### បច្ឆិមពោធិកាល

(អនុសន្ធិ)

**អនុត្តរំ អភិសម្ពោធឹ សម្ពុជ្ឈិត្វា តថាគតោ**
**ធម្មចក្កំ បវត្តេត្វា លោកេ អប្បដិវត្តិយំ ។**

។ល។

*បញ្ចាឡីសមេ វស្សេ វស្សំ វេឡុវគាមកេ*
*ឧបគច្ឆិ មារជេតា វិហាសិ អកុតោភយោ ។*

*កាលសម្តេចព្រះតថាគតសម្ពុទ្ធបរមគ្រូ ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណហើយ ទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ ជាធម៌ដ៏ប្រសើរលើស ដែលឥតមានបុគ្គលណាមួយអាចឲ្យប្រព្រឹត្តទៅស្មើបាន ទ្រង់បំពេញនូវបការកិច្ចប្រទានព្រះពុទ្ធោវាទ ប្រៀនប្រដៅដល់វេនេយ្យសត្វទាំងឡាយ មានបញ្ចវគ្គិយភិក្ខុជាដើម ឲ្យបានត្រាស់ដឹងនូវចតុរារិយ-*

សបុទ្រង់ប្រតិស្ឋានពុទ្ធបរិស័ទទាំង៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ឲ្យស្ថិតនៅក្នុងព្រះសទ្ធម្មនិងលោកុត្តរិយមគ្គ-ផល តាមសមគួរដល់ឧប-និស្ស័យ , ទ្រង់ប្រកាសព្រហ្មចរិយធម៌ឲ្យបរិបូណ៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ជាប្រយោជន៍ដល់មនុស្សនិងទេវតាទាំងឡាយ , ទ្រង់ស្ដេចយាងទៅប្រោសសត្វតាមនិគមជនបទនិងរាជធានីទាំងឡាយ មានក្រុងរាជគ្រឹះក្នុងមគធរដ្ឋជាដើម ទ្រង់ប្រតិស្ឋានពុទ្ធសាសនាលើសត្វទីស្ថាន តាំងតែពីសម័យអភិសម្ពោធិកាលរហូតមកបាន ៤៥ ព្រះវស្សា ។ ក្នុងវស្សាទី ៤៥ ព្រះអង្គទ្រង់ចាំវស្សា ក្នុងស្រុកឈ្មោះវេឡុវគ្រាម តាមពុទ្ធអធ្យាស្រ័យ ។

## ទ្រង់កំណត់ព្រះជន្មាយុសង្ខារ
## (ទ្រង់ស្ដេចពុទ្ធដំណើរទៅវេឡុវគ្រាម)

កត ហិ គ្រានោះព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ស្ដេចយាងចេញចាកអម្ពបា-លីវ័ន ដែលនាងអម្ពបាលីគណិកាថ្វាយជាសង្ឃារាមហើយ ទ្រង់ស្ដេចយាងទៅកាន់ចារិកមួយអន្លើដោយភិក្ខុសង្ឃជាពុទ្ធបរិវារជាច្រើន ដរាបដល់ស្រុកឈ្មោះវេឡុវគ្រាម នាក្រុងវេសាលី ពេលនោះ ជាវេលាជិតវស្សូបនាយិកាសម័យ តាមនៃយានុញ្ញាត ព្រះបរមលោកនាថ

ទ្រង់ត្រាស់ហៅភិក្ខុសង្ឃឲ្យមកប្រជុំគ្នា ទ្រង់អនុញ្ញាតឲ្យភិក្ខុទាំងឡាយ ចាំវស្សាតាមអធ្យាស្រ័យថា ” ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំវស្សាក្នុងត្រីមាសនេះ តាមមិត្តសំឡាញ់នៃខ្លួនរៀង ៗខ្លួនចុះ ឯតថាគតចាំវស្សាក្នុងស្រុកវេឡុវគ្រាមនេះហើយ ព្រះអង្គក៏ទ្រង់អធិដ្ឋានចាំព្រះវស្សាក្នុងស្រុកវេឡុវគ្រាមនោះ ។

លុះនៅកាលជាខាងក្នុងព្រះវស្សា សម្តេចព្រះបរមសាស្តាចារ្យជាម្ចាស់ទ្រង់ប្រឈួនដោយអាពាធដ៏ធ្ងន់ កើតទុក្ខវេទនាស្ទើរតែនឹងស្តេចបរិនិព្វាន តែព្រះអង្គទ្រង់ដំកល់សតិសម្បជញ្ញៈ ទុក្ខវេទនានោះមិនអាចបៀតបៀនធ្វើឲ្យព្រះអង្គក្តៅក្រហាយ ហប់សល់បានទ្រង់អត់សង្កត់ទុក្ខវេទនានោះដោយអធិវាសនខន្តិគុណ ដោយទ្រង់ជ្រាបច្បាស់ថា មិនមែនជាកាលគួរនឹងបរិនិព្វាន ក៏ទ្រង់កំចាត់បង់អាពាធព្យាធិទុក្ខនោះឲ្យស្ងប់រម្ងាប់ទៅបានដោយឥទ្ធិបាទភាវនា ។ លុះព្រះវរកាយរម្ងាប់ចាកអាពាធតាំងទៅជាប្រក្រតីហើយ ថ្ងៃមួយព្រះអង្គទ្រង់គង់លើពុទ្ធាសនៈនៅក្នុងម្លប់នៃព្រះវិហារ ពេលនោះ ព្រះអានន្ទចូលទៅបង្គំគាល់ ថ្វាយអភិវាទនមស្ការក្រាបទូលថា “ ខ្ញុំព្រះអង្គបានឃើញសេចក្តីជាសុខនៃព្រះមានព្រះភាគជាម្ចាស់ហើយ សេចក្តីអត់ធន់នៃព្រះមានព្រះភាគជាម្ចាស់

ខ្ញុំព្រះអង្គបានឃើញហើយ អាស្រ័យហេតុដែលព្រះមានព្រះភាគទ្រង់ប្រឈួនដោយអាពាធដ៏ខ្លាំង ទិសានុទិសទាំងឡាយងងឹតងងុលមិនប្រាកដដល់ខ្ញុំព្រះអង្គដល់តិចតួចសោះ សូម្បីធម៌ទាំងឡាយក៏មិនភ្លឺស្រឡះច្បាស់ដល់ចិត្តរបស់ខ្ញុំព្រះអង្គ ព្រោះមានបរិវិតក្កពិនិត្យដល់អាពាធដែលព្រះអង្គទ្រង់ប្រឈួននោះ ៗ តែនៅមានសេចក្តីត្រេកអរបន្តិចថា ព្រះមានព្រះភាគជាម្ចាស់នៅមិនទាន់បានប្រារព្ធកិច្ចសង្ឃទ្រង់ត្រាស់ពុទ្ធវចនៈណាមួយជាកំណត់ហើយ នឹងមិនបរិនិព្វានឡើយ ខ្ញុំព្រះអង្គមានសេចក្តីត្រេកអរទុកចិត្តបន្តិចដោយហេតុប៉ុណ្ណោះឯង ៗ

ម្នាលអានន្ទ ! កិច្ចទាំងឡាយនៅមានសង្ឃឹមអ្វីចំពោះតថាគតទៀត ធម៌ទាំងឡាយតថាគតបានសំដែងហើយ ធ្វើមិនឲ្យមានខាងក្នុង មិនឲ្យមានខាងក្រៅ ការលាក់បិទបាំងនូវធម៌ទាំងឡាយ មិនមានដល់តថាគតឡើយ ព្រះតថាគតជាសាស្តារបស់ទេវតានិងមនុស្សទាំងឡាយ មានចិត្តផុតស្រឡះចាកតណ្ហានិស្ស័យនិងទិដ្ឋិនិស្ស័យ ដោយប្រការទាំងពួងហើយ អាថ៌ធម៌ដែលត្រូវបិទបាំងទុក ឬថានឹងគប្បីសំដែងឲ្យសាវ័កបានស្តាប់ក្នុងអវសានកាលនេះ-មិនមានឡើយ ៗ

ម្នាលអានន្ទ ! បុគ្គលណានៅមានឆន្ទៈជាប់ដោយសេចក្តីអាល័យថា

នឹងរក្សាភិក្ខុសង្ឃ ឬជាភិក្ខុសង្ឃមានតថាគតជាទីពឹង បុគ្គលនោះឯងគប្បីប្រាប់ភិក្ខុសង្ឃហើយពោលនូវវចនៈណាមួយ ដែលជាការសំដែងសេចក្តីស្នេហាអាល័យ ការពិតដូច្នេះនោះ មិនមានដល់តថាគតឡើយ ។

ម្នាលអានន្ទ! ឥឡូវនេះ តថាគតចាស់ជរាហើយ ជាមនុស្សចាស់ មានវ័យកន្លងហើយ ជន្មាយុកាលនៃតថាគតដល់ ៨០ ឆ្នាំហើយ កាយនៃតថាគតដូចរទេះទ្រុឌទ្រោម ត្រូវគេសង្រួបដោយបុស្សីដែលមិនមែនជាសម្ភារៈរបស់រទេះដូច្នោះ ។

ម្នាលអានន្ទ! សម័យណា តថាគតចូលដល់នូវចេតោសមាធិ គឺការតាំងស៊ប់នៃចិត្តដែលមិនមាននិមិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងឡាយទាំងពួង ព្រោះរលត់ទៅនៃវេទនាហើយនៅ កាលណាព្រះតថាគត ចូលអនិមិត្តចេតោសមាធិ បិតនៅដោយអនិមិត្តសមាធិហើយ កាយនៃតថាគតរមែងមានផាសុកក្នុងសម័យនោះ ។

ម្នាលអានន្ទ! ព្រោះហេតុនៃអនិមិត្តសមាធិវិហារធម៌ ជាហេតុឲ្យកាយមានផាសុកនោះ លោកទាំងឡាយចូរមានខ្លួនជាកោះជាទីពឹង កុំជាអ្នកមានវត្ថុដទៃជាទីពឹងឡើយ គឺចូរមានធម៌ជាទីពឹងនៅគ្រប់ឥរិយាបថចុះ» ព្រះសម្ពុទ្ធបរមគ្រូទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់សំដែងនូវបទដែលជាមាន

ខ្លួនគឺមានធម៌ជាទីពឹងនោះ ដោយអំណាចនៃសតិប្បដ្ឋានទាំង ៤ ហើយទ្រង់ប្រដៅភិក្ខុសង្ឃក្នុងឯកាយនមគ្គ គឺសតិប្បដ្ឋានភាវនា នឹងបកិណ្ណកទេសនាតាមសមគួរដល់ឧប្បត្តិហេតុនោះៗ ហើយ ទ្រង់ស្តេចសម្រាន្តព្រះឥរិយាបថចាំពេញពុទ្ធកិច្ចក្នុងស្រុកឈ្មោះវេឡុវគ្រាម អស់រយៈកាលកន្លងទៅដល់ខែទី ៣ នៃហេមន្តរដូវ ដែលអដ្ឋកថាចារ្យកំណត់ទុកជា ថាថ្ងៃមាឃបុណ្ណមី ដែលព្រះជិនស្រីទ្រង់កំណត់ព្រះជន្មាយុសង្ខារនៅចាបាលចេតិយដ្ឋាន ។

ក្នុងបាលីពោលថា គ្រានោះជាវេលាព្រឹក ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រដាប់ដោយបាត្រនិងចីវរ ស្តេចគោចរបិណ្ឌបាតក្នុងក្រុងវេសាលី លុះវេលាបច្ឆាភត្ត ទ្រង់ស្តេចត្រឡប់អំពីបិណ្ឌបាតវិញ ព្រះអង្គទ្រង់ត្រាស់ព្រះបញ្ជាឲ្យព្រះអានន្ទកាន់យកសំពត់និសីទនៈ សម្រាប់ជាពុទ្ធាសនៈ ទ្រង់ស្តេចយាងទៅកាន់ចាបាលចេតិយ ដើម្បីសម្រាន្តឥរិយាបថក្នុងវេលាថ្ងៃ ។ ព្រះអានន្ទក្រាលសំពត់និសីទនៈ ក្រោមម្លប់ព្រឹក្សមួយថ្វាយចំពោះព្រះបរមសាស្តា ។ ព្រះបរមសាស្តាទ្រង់គង់លើពុទ្ធាសនៈ ។ នៅពេលនោះ ព្រះអានន្ទចូលទៅក្រាបបង្គំគាល់ អង្គុយក្នុងទីដ៏សមគួរមួយ ។ សម្តេចព្រះដ៏មានបុណ្យទ្រង់មានព្រះបំណងឲ្យអានន្ទទូលអារាធ

ា ដើម្បីនឹងស្តេចគង់ព្រះជន្មនៅអស់កាលកំណត់អាយុកប្បមួយ ឬកំ លើសពីអាយុកប្បនោះ ទើបព្រះអង្គទ្រង់ធ្វើនិមិត្តដ៏ច្បាស់ សំដែងអានុភាពនៃឥទ្ធិបាទការនោះថា ឥទ្ធិបាទការនោះទាំង ៤ គឺឆន្ទិទ្ធិបាទ វិរិយិទ្ធិបាទ ចិត្តិទ្ធិបាទ នឹងវិមំសិទ្ធិបាទ ជាធម៌អាចញុំាងបុគ្គលដែលបានចំរើនឲ្យមានអាយុតាំងនៅបានមួយកប្ប ឬ ជាងមួយកប្បបាន ទ្រង់ត្រាស់ឱកាសបរិយាយនិមិត្តដ៏ច្បាស់លាស់ដូច្នេះ អស់វារៈ ៣ ដង មារចូលជ្រៀតជ្រែកចិត្តអានន្ទ ។ មិនដឹងនូវសេចក្តី មិនមានស្មារតីក្រាបទូលអារាធនាបាន ។ ពេលនោះព្រះសុគតជាម្ចាស់ត្រាស់បណ្តេញអានន្ទ ឲ្យចេញចាកទីនោះ ព្រះអានន្ទក៏ក្រាបថ្វាយបង្គំ ប្រទក្សិណហើយទៅគង់ក្រោមម្លប់ឈើមួយដើម មិនឆ្ងាយអំពីព្រះបរមលោកនាថ ។

ព្រះអានន្ទចៀសចេញទៅមិនយូរប៉ុន្មាន មារបានឱកាសចូលទៅគាល់ហើយលើកយកសេចក្តីតាំងពីគ្រាដែលព្រះអង្គបានត្រាស់ដឹងអភិសម្ពោធិញាណ គង់នៅក្រោមដើមអជបាលនិគ្រោធ ដែលទ្រង់ត្រាស់ថា “បរិស័ទទាំង ៤ ពួក គឺភិក្ខុ ភិក្ខុនី, ឧបាសក, ឧបាសិកា នៅមិនទាន់មានប្រាជ្ញាឆ្លាតវាងវៃ អាចសំដែងធម៌ញាំញីបរប្បវាទដោយសហធម៌ ព្រមទាំងព្រហ្មចរិយធម៌ នៅមិនទាន់ប្រកាសផ្សាយបរិបូណ៌ ដោយល្អ

សម្រេចប្រយោជន៍ដល់មហាជនជាច្រើនទាំងទេវតា និងមនុស្សទាំងឡាយ ដរាបណា តថាគតនឹងមិនបរិនិព្វានដរាបនោះ « ឥឡូវនេះ បរិសសម្បត្តិ នឹងព្រហ្មចរិយធម៌ក៏សម្បូណ៌គ្រប់គ្រាន់ដូចពុទ្ធបំណងហើយ សូមព្រះមានព្រះភាគបរិនិព្វានទៅចុះ ឥឡូវនេះ ជាកាលដែលគួរនឹងបរិនិព្វានរបស់ព្រះមានព្រះភាគហើយ » កាលមារពោលដូច្នេះហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា « ម្នាលមារមានចិត្តបាប ! ចូរអ្នកមានសេចក្ដីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគតមិនយូរប៉ុន្មានទេ ចាប់តាំងពីពេលនេះអស់កាល ៣ ខែទៀតតថាគតនឹងបរិនិព្វានហើយ »។

គ្រានោះ សម្ដេចព្រះមានព្រះភាគទ្រង់មានសតិសម្បជញ្ញៈកំណត់ព្រះជន្មាយុសង្ខារ នាចាបាលចេតិយ កើតសេចក្ដីអស្ចារ្យផែនដីកម្រើកញ្ញាប់ញ័រយ៉ាងខ្លាំងគួរខ្លាចស្ញប់ស្ញែងព្រឺរោមព្រឺស្បែក ព្រមទាំងស្គរទិព្វក៏បន្លឺលាន់ឮគឹកកងរំពងពេញទាំងអាកាសវេហាស៍ ។ គ្រានោះព្រះអានន្ទកើតសេចក្ដីអស្ចារ្យក្នុងចិត្ត ទើបក្រោកចេញពីក្រោមម្លប់ឈើចូលទៅក្រាបថ្វាយបង្គំអង្គុយគាល់ព្រះសាស្ដាក្នុងទីដ៏សមគួរមួយ ទូលសួរអំពីហេតុដែលនាំឲ្យកើតសេចក្ដីអស្ចារ្យចំឡែកមានផែនដីញ័រជាដើមនោះៗព្រះមានព្រះភាគទ្រង់ត្រាស់សំដែងហេតុ ៨ ប្រការ ដែលនាំឲ្យផែនដីញ័រយ៉ាងខ្លាំង

ខ្យល់កម្រើក១, បុគ្គលមានឫទ្ធិបណ្ដាល១, ព្រះពោធិសត្វច្យុតចាកតុសិតសួគ៌ចូលចាប់បដិសន្ធិក្នុងព្រះឧទរ១, ព្រះពោធិសត្វប្រសូត្រ១, ព្រះតថាគតត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ១, ព្រះតថាគតទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ១, ព្រះតថាគតទ្រង់កំណត់អាយុសង្ខារ១, ព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ១, ហេតុទាំង ៨ យ៉ាងនេះ កើតឡើងហើយជាបច្ច័យនាំឲ្យផែនដីញ័រ ។ តមកទ្រង់នាំយកព្រះពុទ្ធដម្រាស់ដែលទ្រង់ត្រាស់ដល់មារក្នុងគ្រាដែលគង់នៅក្រោមដើមអជបាលនិគ្រោធ មកត្រាស់ប្រាប់ដល់ព្រះអានន្ទ ហើយទ្រង់ត្រាស់ថា ព្រះអង្គបានដាក់អាយុសង្ខារហើយ អាស្រ័យហេតុនេះទើបផែនដីញ័រ ។

ព្រះអានន្ទទើបក្រាបទូលថា : សូមព្រះមានព្រះភាគទ្រង់គង់នៅអស់មួយកប្បទៅចុះ ដើម្បីជាហិតប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតានឹងមនុស្សទាំងឡាយ, ព្រះមានព្រះភាគទ្រង់ត្រាស់ហាមថា : ម្នាលអានន្ទកុំឡើយ លោកកុំមកអង្វរតថាគតឡើយ ពេលនេះមិនមែនជាកាលដែលអានន្ទគួរមកអង្វរតថាគតទេ » ។ ព្រះអានន្ទក៏ក្រាបទូលអង្វរ ដល់ ២, ៣ ដង ។ ព្រះអង្គទ្រង់ត្រាស់សួរថា: អានន្ទ ! លោកជឿប្រាជ្ញាត្រាស់

ដឹងរបស់តថាគតឬទេ ?

–«បពិត្រព្រះអង្គដ៏ចំរើន ! ខ្ញុំព្រះអង្គដឹង»

–«ម្នាលអានន្ទ ! បើលោកដឹងហើយ ហេតុអ្វីក៏លោកមកអង្វរតថា-គតដល់ទៅ២, ៣ ដង»?

–«បពិត្រព្រះអង្គដ៏ចំរើន ! ខ្ញុំព្រះអង្គបានស្ដាប់ បានទទួលមកចំ-ពោះព្រះភក្ត្រព្រះមានព្រះភាគថា» ឥទ្ធិបាទភាវនា ៤ ប្រការ កាលបុគ្គលណាមួយបានចំរើន បានធ្វើឲ្យច្រើន ស្ទាត់ជំនាញល្អហើយ បើបុគ្គលនោះមានចំណង់នឹងតាំងនៅអស់កាលដ៏យូរដោយរូបកាយ ក៏គប្បី-តាំងនៅបានអស់កាល ១ កប្បឬលើសពី ១ កប្បបាន ឥទ្ធិបាទភាវនាទាំង ៤ នោះ ព្រះតថាគតជាម្ចាស់បានចំរើនស្ទាត់ជំនាញហើយ បើព្រះតថា-គតប្រាថ្នានឹងតាំងនៅ ក៏អាចតាំងនៅអស់កាលអាយុកប្បមួយឬលើសពីអាយុកប្បឡើងទៅបាន» ព្រោះហេតុនោះបានជាខ្ញុំព្រះអង្គក្រាបទូលអង្វរអារាធនាដល់ទៅ ៣ ដងដូច្នេះ» ។

ព្រះមានព្រះភាគទ្រង់ត្រាស់សួរអានន្ទទៀតថា «អានន្ទ ! លោក-ដឹងឬទេ នូវឥទ្ធិបាទភាវនានោះ ?

–«បពិត្រព្រះអង្គដ៏ចំរើន ! ខ្ញុំព្រះអង្គដឹង» ។

—„ម្នាលអានន្ទ ! ហេតុអ្វី កាលតថាគតធ្វើនិមិត្តឱភាសយ៉ាងច្បាស់ ហើយអានន្ទមិនដឹង ? ទាំងមិនបានអង្វរតថាគតក្នុងគ្រានោះ ។ ហេតុនេះ គឺជាការខុសរបស់អានន្ទ បើក្នុងគ្រានោះអានន្ទបានអង្វរតថាគតព្រះ-តថាគតគប្បីហាមអានន្ទអស់វារៈ ២ ដង លុះវារៈទី ៣ ព្រះតថាគតគប្បីទទួលអង្វរករណារបស់អានន្ទហើយ ។ ការដែលអានន្ទមិនបានអង្វរ-តថាគតក្នុងគ្រានោះ ។ គឺជាកំហុសរបស់អានន្ទម្នាក់ឯងប៉ុណ្ណោះ„ ។

លុះព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ ទ្រង់ប្រមូលនិមិត្តឱភាស-ដែលទ្រង់បានធ្វើដល់អានន្ទក្នុងកាលមុន ៗ ចំនួន ១៦ តំបន់ មកសំដែងប្រាប់អានន្ទដោយពិស្តារ ។ ស្ថានទាំង ១៦ តំបន់នោះ ក្នុងក្រុងរាជគ្រឹះ ១០ តំបន់ គឺ នៅក្នុងគិជ្ឈកូដជាទី ១, គោតមនិគ្រោធជាទី ២, ជ្រោះជាទីចោលចោរជាទី ៣, ញកសត្តបណ្ណគូហាក្បែរភ្នំវេភារជាទី ៤, កាឡសិលាជិតភ្នំឥសិគិលិជាទី ៥, សប្បសោណ្ឌិកាក្នុងសីតវ័នជាទី ៦, តបោទារាមជាទី ៧, វេឡុវ័នជាទី ៨, ជីវកម្ពវ័នជាទី ៩, មទ្ទកុច្ឆិមិគទាយវ័នជាទី-១០; ក្នុងក្រុងវេសាលី ៦ តំបន់ គឺ ឧទេនចេតិយជាទី ១, គោតមចេតិយជាទី ២, សត្តម្ពចេតិយជាទី ៣, ពហុបុត្តកចេតិយជាទី ៤, សារន្ទទចេតិយជាទី ៥(១), បាវាលចេតិយជាទី ៦ រួមជា ១៦ តំបន់ ។

---

១ ក្នុងបាលី សារន្ទចេតិយ

ក្នុងរាត្រីទី ១៦ ជាកាលដែលអានន្ទគួរអង្វរករព្រះតថាគត តែអានន្ទមិនបានដឹង មិនបានអង្វរករព្រះតថាគតទៀត បើក្នុងរាត្រីទី ១៦ នោះណាមួយ អានន្ទបានអង្វរករព្រះតថាគត ៗ គប្បីហាមឃាត់អានន្ទតែត្រឹម ២ ដងប៉ុណ្ណោះ លុះរាត្រីជាគម្រប់ ៣ ដង ព្រះតថាគតនឹងទទួលអង្វរកររបស់អានន្ទ ការដែលអានន្ទមិនបានដឹងមិនបានអង្វរករព្រះតថាគតនេះ ជាសេចក្ដីខុសរបស់អានន្ទតែម្នាក់ឯង ៗ

"ម្នាលអានន្ទ! តថាគតបានប្រាប់ហើយថា; បណ្ដាសត្វនិងសង្ខារដែលជាទីស្រឡាញ់គាប់ចិត្តទាំងពួងរមែងប្រព្រឹត្តទៅផ្សេង ៗ ផ្លាស់ប្ដូរទៅជាប្រការដទៃ មិនតាំងនៅជាស្ថាពរតាមចិត្តប្រាថ្នាឡើយ; ឯរបស់ដែលទៀងទាត់ ដែលសត្វទាំងឡាយមានសេចក្ដីប៉ុនប៉ងចង់បានណាស់នោះ សត្វទាំងឡាយមិនគប្បីបានក្នុងសង្ខារទាំងឡាយនោះទេ របស់ណាដែលកើតមកដោយអាស្រ័យបច្ច័យតាក់តែងឡើង របស់នោះតែងមានសេចក្ដីវិនាសទៅវិញជាធម្មតា សត្វទាំងឡាយមានប្រាថ្នាអន្ទះ-អន្ទែងថា សូមឲ្យរបស់នោះ កុំវិនាសទៅឡើយដូច្នេះ មិនមែនជាឋានៈដែលឲ្យបានសម្រេចតាមសេចក្ដីប្រាថ្នាឡើយ ៗ

"ម្នាលអានន្ទ! ដែលរបស់ណាតថាគតបានលះបង់ហើយ បាន

បន្សាត់បង់ហើយ បានប្រានចោលហើយ បានលះលែងហើយ បាន
ដាក់ចុះហើយ ព្រះតថាគតមិនត្រឡប់មកកាន់របស់នោះវិញ ព្រោះ
ហេតុនៃជីវិត" ដូច្នេះមិនមានទៀយ ។

## ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ
## (ស្តេចយាងទៅព្រៃមហាវ័ន)

កាលព្រះមានព្រះភាគទ្រង់ត្រាស់ដល់ព្រះអានន្ទដូច្នោះហើយ ទ្រង់
ស្តេចពុទ្ធដំណើរទៅកាន់កូដាគារសាលានាព្រៃមហាវ័ន ត្រាស់បង្គាប់
ឲ្យអានន្ទរកហៅភិក្ខុទាំងឡាយដែលអាស្រ័យនៅក្នុងក្រុងវេសាលី ឲ្យមក
ប្រជុំគ្នាក្នុងឧបដ្ឋានសាលា ហើយព្រះអង្គទ្រង់ស្តេចយាងទៅប្រថាប់លើ
ពុទ្ធាសនៈ ទ្រង់ប្រទានឱវាទប្រដៅភិក្ខុទាំងឡាយដោយអភិញ្ញាទេ-
សិតធម៌ថា៖

"ម្នាលភិក្ខុទាំងឡាយ! លោកទាំងឡាយនៅមានសេចក្តីប្រាថ្នាឲ្យ
តថាគតគង់នៅអស់កាលយូរដើម្បីប្រយោជន៍នឹងសេចក្តីសុខ ដល់មហា-
ជនច្រើនទៀត ធម៌ទាំងឡាយណា ដែលតថាគតបានទេសនាទុកដោយ
ប្រាជ្ញាដ៏ក្រៃលែង សំដែងទុកដើម្បីការត្រាស់ដឹងចំពោះ (មុខ) ក្នុង
ផុតលោកិយញ្ញាណ បន្ទុះលោកុត្តរបញ្ញា ធម៌ទាំងឡាយនោះ លោក

ទាំងឡាយគប្បីរៀន ឲ្យល្អឲ្យសម្រេចប្រយោជន៍ ដោយសេចក្ដីគោរពអើពើតាមពិត គប្បីសេព គប្បីចម្រើន គប្បីធ្វើឲ្យច្រើនក្នុងសន្តានថែបនេះ ព្រហ្មចារិយធម៌នឹងគប្បីតាំងនៅអស់កាលជាយូរមិនសាបសូន្យ ទាំងគប្បីប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងសេចក្ដីសុខដល់មហាជន គប្បីអនុគ្រោះដល់សត្វលោក ដើម្បីហិតសុខដល់ទេវតានិងមនុស្សទាំងឡាយ, ធម៌ទាំងឡាយដែលយើងបានសំដែងដោយបញ្ញាដ៏ក្រៃលែងនោះគឺអ្វី ? ធម៌នោះគឺ សតិបដ្ឋាន ៤, សម្មប្បធាន ៤, ឥទ្ធិបាទ ៤, ឥន្ទ្រិយ ៥, ពល ៥, ពោជ្ឈង្គ ៧, មគ្គមានអង្គ ៨ ប្រការ ទាំងនេះឈ្មោះថាអភិញ្ញាទេសិតធម៌ លោកទាំងឡាយគប្បីរៀនឲ្យល្អ គប្បីចម្រើន គប្បីធ្វើឲ្យច្រើនក្នុងសន្តានចុះ ព្រះតថាគតសម្មាសម្ពុទ្ធគប្បីគង់នៅដើម្បីប្រយោជន៍ណា ប្រយោជន៍នោះនឹងសម្រេចដល់ទេវតានិងមនុស្សទាំងឡាយច្រើន„ ។

លំដាប់នោះព្រះមានព្រះភាគ ទ្រង់ប្រៀនប្រដៅភិក្ខុទាំងឡាយដោយសំនួនថានឹងអប្បមាទធម៌ថា: ម្នាលភិក្ខុទាំងឡាយ! ឥឡូវនេះតថាគត យើងតឿនលោកទាំងឡាយឲ្យបានដឹងថា សង្ខារធម៌ដែលបច្ច័យតាក់តែងឡើងហើយតែងមានសេចក្ដីសូន្យទៅជាធម្មតា ចូរអ្នកទាំង-

ឡាយញុំាងប្រយោជន៍ខ្លួនផងប្រយោជន៍អ្នកដទៃ ឲ្យដល់ព្រមគ្រប់គ្រាន់ដោយសេចក្ដីមិនប្រមាទចុះ ព្រះតថាគតនឹងបរិនិព្វានក្នុងកាលមិនយូរប៉ុន្មានដោយកាលកន្លងទៅតែ ៣ ខែប៉ុណ្ណោះ តាំងអំពីថ្ងៃនេះទៅ ។ ជនទាំងឡាយណានោះជាមនុស្សក្មេងក្ដី ចាស់ក្ដី ពាលក្ដីបណ្ឌិតក្ដី មានក្ដី ក្រក្ដី ជនទាំងឡាយនោះសុទ្ធតែមានសេចក្ដីស្លាប់ជាទីប្រព្រឹត្តទៅក្នុងខាងមុខទាំងអស់ភាជនៈ ដី គឺ ជាជនបានធ្វើហើយ ទាំងតូចទាំងធំដុតក្ដីមិនបានដុតក្ដី បណ្ដាភាជនៈទាំងឡាយនោះ មិនជាមានខ្នាតប៉ុណ្ណា សុទ្ធតែមានការបែកធ្លាយទៅជាទីបំផុត សេចក្ដីនេះយ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏មានការបែកធ្លាយវិនាសទៅជាទីបំផុតយ៉ាងនោះដែរ ។ វ័យរបស់តថាគតចាស់ដោយជុំវិញហើយ ជីវិតរបស់តថាគតតិចណាស់ហើយ តថាគតនឹងលះបង់អ្នកទាំងឡាយទៅ ឯទីពឹងតថាគតបានធ្វើទុកហើយ ។

"ម្នាលភិក្ខុទាំងឡាយ ! លោកទាំងឡាយចូរជាអ្នកមិនប្រមាទ ចូរជាអ្នកមានសតិ ចូរជាអ្នកមានសីលល្អ ចូរជាអ្នកមានសេចក្ដីត្រិះរិះល្អចូរជាអ្នកតាមរក្សានូវចិត្តរបស់ខ្លួន បុគ្គលណាជាអ្នកមិនប្រមាទក្នុងធម្មវិន័យ បុគ្គលនោះនឹងលះបង់នូវជាតិសង្សារ គឺការក្រោបអន្ទោលទៅដោយ

កំណើត ធ្វើនៅទីបំផុតនៃសេចក្ដីទុក្ខបាន ។ សម្ដេចព្រះសុគតបរមលោកនាថ ទ្រង់ប្រកាសប្រាប់សាវ័ក ក្នុងសេចក្ដីសង្រួមនិងសេចក្ដីមិនប្រមាទ ដោយប្រការដូច្នេះ ៗ

គ្រានោះ នៅវេលាព្រឹកជាវេលាភិក្ខាចារកាល ព្រះដ៏មានបុណ្យទ្រង់ខ្វាត្របាត្រនិងចីវរស្ដេចយាងចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ៗ លុះពេលបច្ឆាភត្ត ព្រះអង្គទ្រង់ត្រឡប់អំពីបិណ្ឌបាតវិញ ទ្រង់ទតព្រះនេត្រមើលក្រុងវេសាលីជានាគាវលោក (១) ហើយទ្រង់ស្ដេចត្រឡប់បែរទាំងព្រះកាយដោយអាការនៃមហាបុរស ត្រាស់ហៅអានន្ទថា:

" អានន្ទ ! មក ! យើងទៅកាន់ស្រុកភណ្ឌុគ្រាម

អថខោ គគក់ គ្រានោះព្រះដ៏មានព្រះភាគ ព្រមទាំងភិក្ខុសង្ឃច្រើនអង្គជាបរិវារ ទ្រង់ស្ដេចយាងដល់ស្រុកភណ្ឌុគ្រាម ទ្រង់គង់នៅស្រុកភណ្ឌុគ្រាមនោះ ត្រាស់ទេសនាអំពីសីល សមាធិ បញ្ញានិងវិមុត្តិ ជាអរិយធម៌ ៤ ប្រការថា:

" ម្នាលភិក្ខុទាំងឡាយ! អាស្រ័យហេតុគឺការមិនត្រាស់ដឹងមិនចាក់ធ្លុះនូវអរិយធម៌ ៤ ប្រការគឺសីល សមាធិបញ្ញា និងវិមុត្តិ បានជាតថាគត

---

(១) សំឡឹងរបៀបដំរីងាកក្រោយ (ការមើលជាទីបំផុត)

ដែលជាសាស្តានិងលោកទាំងឡាយជាសាវ័ក ត្រូវក្រាបផ្តាត់អស់ខ្នោល ទៅមកដោយជាតិកំណើតក្នុងភពតូចធំអស់កាលយូរអង្វែងយ៉ាងនេះ ។ មោហៈ គឺសេចក្តីវង្វេងងងឹតវិលវល់ជាគ្រឿងបិទបាំងបញ្ញាមិនឲ្យត្រាស់ដឹងនូវធម៌ទាំង ៤ ប្រការនេះជាហេតុនាំឲ្យតថាគតនិងលោកទាំងឡាយ សោយសង្សារទុក្ខជាអនេកប្បការ ។

"ម្នាលភិក្ខុទាំងឡាយ ! ឥឡូវនេះ សីល សមាធិ បញ្ញានិងវិមុត្តិ ដែលជាអរិយធម៌នោះតថាគតនិងលោកទាំងឡាយបានត្រាស់ដឹងហើយ បានចាក់ធ្លុះចំពោះហើយ តណ្ហាដែលជាហេតុឲ្យកើតក្នុងភពគឺតថាគតនិងអ្នកទាំងឡាយបានកាត់ផ្តាច់ហើយ តណ្ហាដែលជាគ្រឿងនាំទៅក្នុងភពដូចជាខ្សែដែលចងជាប់ទៅនឹងជើងក្អកអស់ហើយ តណ្ហានោះមិនអាចសាងភពណាមួយបានទៀតឡើយ ឥឡូវនេះ ការកើតទៀតរបស់តថាគតក្តី របស់លោកទាំងឡាយក្តី មិនមានទេ" ។

កាលដែលព្រះដ៏មានបុណ្យទ្រង់គង់នៅក្នុងស្រុកកណ្ឌុគ្រាមនោះព្រះអង្គត្រាស់ធម្មីកថា សំដែងអំពី សីល សមាធិ បញ្ញា ប្រៀនប្រដៅភិក្ខុទាំងឡាយច្រើនជាងកថាដទៃ ហើយទ្រង់សំដែងអានិសង្សនៃត្រៃសិក្ខានេះថា

" សីលជាទីតាំងដ៏ធំនៃគុណវិសេសថ្នាក់លើ ដូចជាផែនដី

ដែលជាទីអាស្រ័យនៃការងារទាំងឡាយ សីលបរិសុទ្ធជាគ្រឿងអប់រំសមាធិ សមាធិជាគុណធម៌មានអានិសង្សច្រើនក្រៃលែង សមាធិអប់រំបញ្ញា បញ្ញាជាគុណជាតិមានផលានិសង្សធំលើសលុប បញ្ញាអប់រំចិត្ត ចិត្តដែលបញ្ញាបានអប់រំហើយ រមែងដល់នូវវិមុត្តិផុតចាកអាសវៈទាំងឡាយដែលជាគ្រឿងត្រាំក្នុងសន្តាន គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ទិដ្ឋាសវៈ ទាំងពួងឲ្យវិនាសសូន្យទៅឥតមានសេសសល់ឡើយ សិក្ខាទាំង ៣ នេះជាបដិបទានៃវិមុត្តិ ១ ជាសារៈនៃធម្មវិន័យ សាវ័កទាំងឡាយដែលបានសម្រេចនូវវិមុត្តិនោះ ក៏ព្រោះបានធ្វើឲ្យបរិបូណ៌ក្នុងត្រៃសិក្ខានោះឯង ។

## ទ្រង់ស្ដេចយាងទៅភោគនគរ

គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចទ្រង់ធ្វើសត្ថុបការកិច្ចក្នុងស្រុកភណ្ឌគ្រាមតាមពុទ្ធអធ្យាស្រ័យហើយ ៗ តមកទ្រង់ស្ដេចយាងទៅកាន់ស្រុកហត្ថិគ្រាម , អម្ពគ្រាមនិងជម្ពុគ្រាម តាមលំដាប់ដរាបដល់ភោគនគរ ទ្រង់គង់សម្រាកព្រះឥរិយាបថក្នុងអានន្ទចេតិយស្ថានក្នុងភោគនគរនោះ ទ្រង់សំដែងទេសនាមហាបទេសផ្នែកខាងព្រះសូត្រ ៤ យ៉ាងប្រដៅភិក្ខុទាំងឡាយ ដើម្បីជាគ្រឿងកំណត់ឲ្យដឹងនូវភាសិតណាៗថា ជាធម៌ ជាវិន័យ ជាសត្ថុសាសនា ឬមិនមែនជាធម៌ មិន

មែនជាវិន័យ មិនមែនជាសត្ថុសាសនា ។

សេចក្តីក្នុងមហាបទេសទាំង ៤ នោះថា: " បើមានភិក្ខុមកអាងព្រះសាស្តា អាងសង្ឃ អាងគណៈឬអាងបុគ្គលក៏ ហើយសំដែងថា "នេះជាធម៌ នេះជាវិន័យ នេះជាសត្ថុសាសនា ដូច្នេះ ដល់បុគ្គលណាមួយ លោកដែលបានស្តាប់ហើយ កុំគប្បីប្រញាប់ត្រេកអរទទួលភាសិតរបស់ភិក្ខុដែលមកអាងនោះ ហើយកុំប្រញាប់បដិសេធភាសិតនោះពោលទៀយ គប្បីរៀនបទព្យញ្ជនៈឲ្យបេះពិតប្រាកដ គប្បីពិនិត្យមើលក្នុងព្រះសូត្រ គប្បីប្រៀបធៀបគ្នាក្នុងព្រះវិន័យ បើភាសិតនោះស្របក្នុងព្រះសូត្រ ធៀបក្នុងព្រះវិន័យមិនបានទេ គប្បីសន្និដ្ឋានចូលចិត្តថាមិនមែនជាពុទ្ធវចន ភិក្ខុនេះទទួលមកខុស នាំមកឃៀងឃ្លាតហើយ ។ កាលណាមានន័យស្របគ្នាក្នុងព្រះសូត្រ ប្រៀបធៀបគ្នាក្នុងព្រះវិន័យបានមិនខុសមិនឃៀងឃ្លាតនោះ គប្បីសន្និដ្ឋានថា នេះជាពាក្យរបស់ព្រះមានព្រះភាគ ភិក្ខុនោះបានទទួលស្តាប់នាំមកដោយល្អមិនវិបរិត ។ អត្ថនេះជាសេចក្តីសង្ខេបក្នុងមហាបទេសដែលមានអាងធំ ៤ យ៉ាងផ្អែកទៅព្រះសូត្រ ។

គ្រានោះព្រះអង្គទ្រង់សំដែងធម្មិកថាអំពីសិក្ខាដូចន័យមុនជាពហុលកថា ច្រើនជាងកថាដទៃ តាមសមគួរដល់វេនេយ្យសត្វនឹងកាលសម័យ ។

# នាយចុន្ទថ្វាយបច្ឆិមបិណ្ឌបាត

## ( ទ្រង់ស្តេចយាងទៅនគរបាវា )

កាលព្រះបរមគ្រូស្តេចប្រថាប់នៅក្នុងភោគនគរតាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ខែនិងថ្ងៃចេះតែកន្លងទៅជាលំដាប់ ជិតដល់កំណត់តាមកតិកាដែលទ្រង់ដាក់ព្រះជន្មាយុសង្ខារហើយ ព្រះបរមលោកនាថព្រមទាំងភិក្ខុសង្ឃជាពុទ្ធបរិវារ ទ្រង់ស្តេចយាងដល់នគរបាវា ទ្រង់ប្រថាប់នៅក្នុងនគរអម្ពវ័នព្រៃស្វាយរបស់នាយចុន្ទៈជាបុត្តនៃជាងមាស ។ នាយចុន្ទកម្មារបុត្តបានដឹងថាព្រះដ៏មានបុណ្យទ្រង់ស្តេចយាងមកដល់នគរបាវាហើយ ឥឡូវនេះស្តេចគង់នៅក្នុងព្រៃស្វាយរបស់ខ្លួន ទើបទៅថ្វាយបង្គំគាល់ព្រះបរមលោកនាថក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ទេសនាធម្មីកថាប្រោសឲ្យនាយចុន្ទកម្មារបុត្របានឃើញក្នុងផលកម្មនិងវិបាក ឲ្យប្រកាន់យកក្នុងកុសលចរិយា ឲ្យមានសេចក្តីក្លាហានក្នុងធម្មចរិយាសម្មាបដិបត្តិ ។ នាយចុន្ទកម្មារបុត្របានក្រាបទូលនិមន្តព្រះអង្គដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែកថា:

“ សូមព្រះមានព្រះភាគជាម្ចាស់ ព្រមទាំងភិក្ខុសង្ឃទទួលភត្តាហាររបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ” សម្តេចព្រះមានបុណ្យទ្រង់ទទួល

និមន្តដោយតុណ្ហីភាព ។ នាយចុន្ទកម្មារបុត្រដឹងថាព្រះអង្គទ្រង់ទទួលហើយ ក្រាបថ្វាយអភិវាទធ្វើប្រទក្សិណហើយជៀសចេញទៅ ។

## ទ្រង់ព្រះប្រឈួន
## ស្ដេចយាងទៅនគរកុសិនារា

កាលសម្ដេចព្រះមានព្រះភាគទ្រង់ឆាន់ភត្តាហាររបស់នាយចុន្ទៈស្រេចហើយ ក៏កើតជរាពាធដ៏ខ្លាំងក្លា ទ្រង់ប្រឈួនដោយធ្លាក់ព្រះលោហិតកើតវេទនាសាហាវស្ទើរតែនឹងបរិនិព្វាន ព្រះអង្គមានព្រះសតិសម្បជញ្ញៈទ្រង់មិនត្រវល់ក្រវាយ ទ្រង់អត់សង្កត់នូវទុក្ខវេទនានោះដោយអធិវាសនខន្តិគុណ ។ គ្រានោះព្រះអង្គទ្រង់ត្រាស់ហៅព្រះអានន្ទថា " ម្នាលអានន្ទ! មក! យើងទៅជាមួយគ្នា ទៅនគរកុសិនារា "ព្រះអានន្ទទទួលពុទ្ធាណត្តិ ប្រាប់ដល់ភិក្ខុសង្ឃទាំងឡាយឲ្យដឹងគ្រប់អង្គហើយ ព្រះមានព្រះភាគក៏ស្ដេចយាងតាមមាគ៌ាជាទីសញ្ចារទៅនគរកុសិនារា លុះស្ដេចយាងមកដល់ពាក់កណ្ដាលមាគ៌ា ទ្រង់លំបាកព្រះកាយខ្លាំងណាស់ ទើបទ្រង់ស្ដេចយាងចូលទៅប្រថាប់ក្រោមម្លប់ព្រឹក្ស ១ ដើម ត្រាស់ពុទ្ធបញ្ជាដល់ព្រះអានន្ទថា " អានន្ទ ! មកឆាប់ឡើង ! លោកចូលក្រាលសំពត់សង្ឃាដិគម្រងជា ៤ ជាន់ឲ្យតថា-

គត តថាគតនឿយណាស់ តថាគតនឹងសម្រាកបំបាត់សេចក្ដីលំបាក កាយ (បន្តិច)" ។ ព្រះអានន្ទក៏ក្រាលសំពត់សង្ឃាដិថ្វាយ ព្រះអង្គទ្រង់គង់ហើយត្រាស់ហៅអានន្ទថា " អានន្ទ! លោកចូរទៅដងទឹកសម្រាប់ឆាន់មកឲ្យតថាគត តថាគតនឹងឆាន់រំងាប់សេចក្ដីក្រហាយ (ស្រេក) ឲ្យស្ងប់" អានន្ទក្រាបទូលថា "បពិត្រព្រះអង្គដ៏ចំរើន រទេះប្រមាណ ៥០០ ទើបនឹងឆ្លងហើយអំបាញ់មិញនេះ . ទឹកក្នុងស្ទឹងនេះមានតិច ត្រូវកង់នឹងជើងគោដើរល្អុកល្អុយល្អក់អស់ទៅហើយ មិនគួរយកមកឆាន់ទេ ចាំដល់ស្ទឹងកកុធានទី មានទឹកថ្លាស្អាតត្រជាក់ល្អមានកំពង់ល្អគួរជាទីមនោរម្យ នៅមិនឆ្ងាយប៉ុន្មាន សូមព្រះអង្គស្ដេចយាងទៅបន្តិចទៀតនឹងដល់ស្ទឹងនោះ ទ្រង់សោយហើយជម្រះព្រះវរកាយឲ្យត្រជាក់ជាសុខសម្រាន្ត" ព្រះបរមលោកនាថទ្រង់ត្រាស់បញ្ជាព្រះអានន្ទដល់ទៅ ៣ ដង ព្រះអានន្ទក្រាបទូលជំទាស់ ២ ដង លុះវារៈទី ៣ ព្រះអានន្ទមិនបានក្រាបទូលជំទាស់ឡើយ ដោយសារមានសតិរលឹកដឹងថា " ធម្មតាព្រះតថាគតជាសម្មាសម្ពុទ្ធទាំងឡាយ មិនដែលទ្រង់មានព្រះវាចាដោយមិនមានហេតុឡើយ " លោកទទួលពុទ្ធបញ្ជាហើយ ទើបយកបាត្រឥមន្តទៅកាន់ស្ទឹងនោះ ដោយអំណាច

ពុទ្ធានុភាពមកបណ្ដាល ក្នុងឲ្យអស្ចារ្យណាស់ នៅវេលាដែលព្រះអានន្ទចូលទៅជិត បម្រុងនឹងដងទឹកមកថ្វាយ ស្រាប់តែទឹកដែលកករល្អក់ដោយកង់រទេះនៃនាយឈ្មួញទាំងឡាយ ក៏ប្រែក្លាយទៅជាទឹកថ្លាស្អាតបរិសុទ្ធទៅវិញ ។ ព្រះអានន្ទលោកឃើញដូច្នោះហើយក៏រិះគិតថា " ភាវៈនៃព្រះតថាគតដែលទ្រង់មានឫទ្ធានុភាពដ៏លើសលុបជាអស្ចារ្យ. ដែលមិនធ្លាប់មានផងឡើយមានឡើងហើយ ទឹកក្នុងស្ទឹងនេះកករល្អក់ណាស់តែដល់អាត្មាអញចូលទៅជិតបម្រុងនឹងដង ទឹកក៏ក្លាយទៅជាថ្លាស្អាតបរិសុទ្ធ " ។ ព្រះអានន្ទលោកចុះទៅដងទឹកសម្រាប់ឆាន់ដោយបាត្រហើយមានសេចក្ដីរីករាយ នាំចូលទៅថ្វាយព្រះដ៏មានបុណ្យ ស្ដេចទ្រង់សោយហើយ ទ្រង់ប្រថាប់នៅក្រោមម្លប់ព្រឹក្សានោះ ។

សម័យនោះ បុត្រនៃមល្លក្សត្រ ១ អង្គ ទ្រង់ព្រះនាមថាបុក្កុសៈ ជាសាវកៈរបស់អាឡារតាបស កាលាមគោត្រចេញអំពីក្រុងកុសិនារាទៅកាន់នគរបាវា លុះមកដល់ក្នុងទីនោះ បានឃើញព្រះភគវត្តមុនី កំពុងស្ដេចគង់ក្រោមម្លប់ឈើ ចូលទៅអភិវាទថ្វាយបង្គំហើយអង្គុយនៅក្នុងទីដ៏សមគួរ បានស្ដាប់សន្តិវិហារធម៌របស់ព្រះដ៏មានបុណ្យក៏មានចិត្តជ្រះថ្លាបង្អោនគូនៃសំពត់សិង្គីវណ្ណៈ ចូលទៅថ្វាយសម្ដេចព្រះដ៏មានបុណ្យ

ក្រាបទូលថា " បពិត្រព្រះដ៏មានព្រះភាគ ! សំពត់សាច់ល្អិតមានពណ៌ដូចមាសសិង្គិតាំងគូរបស់ខ្ញុំព្រះអង្គនេះ ជាសំពត់ពិសេស ជារបស់ប្រណីត ដែលខ្ញុំព្រះអង្គបរិក្សាទុកសម្រាប់ប្រើប្រាស់មួយកាល ១ គ្រា សូមព្រះដ៏មានព្រះភាគអាស្រ័យសេចក្តីអនុគ្រោះទទួលនូវសំពត់សិង្គិវណ្ណៈរបស់ខ្ញុំព្រះអង្គចុះ " ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា " បើដូច្នោះអ្នកចូរឲ្យតថាគតបិទបាំងកាយដោយសំពត់សិង្គិវណ្ណៈ ១ ។ ចូរឲ្យអានន្ទបិទបាំងកាយដោយសំពត់សិង្គិវណ្ណៈ ១ " ។ បុក្កុសមល្លបុត្រក៏ថ្វាយជាពុទ្ធបរិភោគ ១ ផ្ទាំង ១ ផ្ទាំងទៀតប្រគេនព្រះអានន្ទតាមពុទ្ធបញ្ជាន ។ សម្តេចព្រះដ៏មានបុណ្យទ្រង់សំដែងធម្មីកថា ញ៉ាំងបុក្កុសមល្លបុត្រ ឲ្យមានសេចក្តីជ្រះថ្លារីករាយក្នុងកុសលធម្មចរិយាតាមសមគួរហើយ បុក្កុសមល្លបុត្រក៏ថ្វាយអភិវាទបង្គំធ្វើប្រទក្សិណហើយ ចៀសចេញទៅ ។

( សម្បុរកាយព្រះតថាគតផ្ទូរផង់ ២ កាល )

កាលបុក្កុសមល្លបុត្រចៀសចេញទៅមិនយូរប៉ុន្មានព្រះអានន្ទក៏បង្អោននូវសំពត់សិង្គិវណ្ណៈនោះចូលទៅដល់ព្រះវរកាយ នៃព្រះមានព្រះភាគជាម្ចាស់ ព្រះដ៏មានបុណ្យស្តេចទ្រទ្រង់សំពត់សិង្គិវណ្ណទាំង ២ ផ្ទាំងនោះ

ដោយធ្វើជាអន្តរវាសក១ផ្ទាំង ធ្វើជាឧត្តរាសង្គ១ផ្ទាំងៗ តែនៅសំពត់សិង្គិវណ្ណទាំងពីរផ្ទាំងនោះ ប្រាកដហាក់ដូចជារលើករលីង លុះអានន្ទបង្អោនទៅដល់ព្រះកាយហើយ វណ្ណៈរបស់ព្រះកាយនៃព្រះតថាគត ក៏បរិសុទ្ធផូរផង់ល្អប្លែក ព្រះអានន្ទត្រេកអរទូលសរសើរថា " ព្រះឆវីវណ្ណនៃព្រះតថាគតបរិសុទ្ធជាអស្ចារ្យក្រៃពេកណាស់ ។ ព្រះអង្គទ្រង់ត្រាស់ថា " ម្នាលអានន្ទ ! ឆវីវណ្ណនៃព្រះតថាគតបរិសុទ្ធផូរផង់ដូចអានន្ទសរសើរពិត កាយនៃព្រះតថាគត រមែងបរិសុទ្ធថ្លាស្អាតឆវីវណ្ណនៃព្រះតថាគតបរិសុទ្ធផូរផង់ហាក់ក្រៃលែងក្នុង ២ កាល គឺក្នុងរាត្រីដែលព្រះតថាគតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ១ ក្នុងរាត្រីដែលព្រះតថាគតចូលបរិ-និព្វានដោយអនុបាទិសេសនិព្វានធាតុ ១ ក្នុង ២ កាលនេះ កាយព្រះតថាគតបរិសុទ្ធក្រៃពេកណាស់ ឆវីវណ្ណព្រះតថាគតផូរផង់ថ្លាស្អាតដោយពិសេស, ម្នាលអានន្ទ! ក្នុងទីបំផុតនៃរាត្រីថ្ងៃនេះហើយ ព្រះត-ថាគតនឹងបរិនិព្វានក្នុងចន្លោះនៃដើមសាលព្រឹក្ស(១) ទាំងគូ ក្នុងសាលវ-នោទ្យាននៃមល្លក្សត្រទាំងឡាយ ក្នុងនគរកុសិនារា ម្នាលអានន្ទ ! លោកចូរមកយើងទៅកាន់ស្ទឹងកកុធានទី " ។ ព្រះអានន្ទបានទទួលពុទ្ធាណត្តិហើយប្រាប់ភិក្ខុសង្ឃឲ្យជ្រាប ។

(១) សាលៈជាឈើមានស្លឹកធំក្រាស់មានផ្កាស្រដៀងនិងផ្កាស្រគីតែធំជាង ។

លំដាប់នោះ សម្តេចព្រះដ៏មានបុណ្យព្រមទាំងភិក្ខុសង្ឃជាពុទ្ធបរិវារជាច្រើន ទ្រង់ស្តេចយាងទៅដល់ស្ទឹងកកុធានទីហើយ ស្តេចទ្រង់ស្រង់ស្រោចស្រប់ព្រះកាយជាសុខសម្រាន្ត តាមពុទ្ធអធ្យាស្រ័យហើយ ទ្រង់ស្តេចយាងទៅប្រថាប់ក្នុងអម្ពវ័ន ត្រាស់ហៅព្រះចុន្ទកត្ថេរឲ្យលាតសំពត់សង្ឃាដិ ៤ ជាន់ថ្វាយ ព្រះអង្គសម្រេចសីហសេយ្យាដោយព្រះភក្ត្របែរទៅខាងស្តាំ ដាក់ព្រះបាទតម្រួតលើព្រះបាទមានសតិនិងសម្បជញ្ញៈ ធ្វើទុកក្នុងព្រះទ័យ នូវឧដ្ឋានសញ្ញាសេចក្តីសំគាល់ក្នុងការក្រោកឡើង, ព្រះចុន្ទត្ថេរលោកគង់គាល់នៅក្នុងទីចំពោះព្រះភក្ត្រក្នុងទីនោះ ។

## បិណ្ឌបាតទាន ២ គ្រាមានផលស្មើគ្នា

លំដាប់នោះ ព្រះមានព្រះភាគ ព្រះអង្គទ្រង់ដល់ហើយដោយវិសេសក្នុងបាទបានសញ្ញាណ ត្រាស់ហៅព្រះអានន្ទថា "ម្នាលអានន្ទ ហេតុការណ៍នេះនឹងគប្បីមាន បើមានបុគ្គលណាមកធ្វើវិប្បដិសារីសេចក្តីក្តៅក្រហាយឲ្យកើតឡើងដល់នាយចុន្ទកម្មារបុត្រថា" ម្នាលនាយចុន្ទ- មិនមែនជាលាភរបស់អ្នកទេ អ្នកជាមនុស្សមិនល្អទេ ព្រះតថាគតជាម្ចាស់ទ្រង់សោយនូវបិណ្ឌបាតទានរបស់អ្នកជាទីបំផុត ហើយស្តេចទ្រង់ចូល

បរិនិព្វានដូច្នេះ ម្នាលអានន្ទ ! វិប្បដិសារីសេចក្តីក្តៅក្រហាយរបស់នាយចុន្ទកម្មារបុត្រនោះ លោកទាំងឡាយគប្បីរម្ងាប់ឲ្យស្ងប់ដោយនិយាយប្រលោមថា (ម្នាលនាយចុន្ទ ! ជាលាភយ៉ាងប្រសើររបស់អ្នកហើយ អ្នកជាមនុស្សល្អហើយ ព្រះតថាគតជាម្ចាស់ បានឆាន់នូវបិណ្ឌបាតទានរបស់អ្នកជាគ្រាចុងបំផុតហើយស្តេចបរិនិព្វាន, ម្នាលនាយចុន្ទ ! សេចក្តីនេះ យើងបានស្តាប់មកហើយ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគថា ,,បិណ្ឌបាតទាន២យ៉ាងមានផលស្មើគ្នា មានវិបាកស្មើគ្នា មានផលច្រើនមានអានិសង្សធំទូលាយជាងបិណ្ឌបាតទានដទៃៗ គឺព្រះតថាគតទ្រង់សោយបិណ្ឌបាតទានណាហើយ បានសម្រេចអនុត្តរសម្មាសម្ពោធិ-ញាណ បិណ្ឌបាតទាននោះ ១ ព្រះតថាគតទ្រង់សោយនូវបិណ្ឌបាតទានណាហើយ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ បិណ្ឌបាតទាននោះ ១ បិណ្ឌបាតទានទាំង ២ យ៉ាងនេះ មានផលមានវិបាកប៉ុនគ្នា បានអានិសង្សធំទូលាយជាងបិណ្ឌបាតទានទាំងឡាយដទៃៗ ។ ធម៌ដែលឲ្យអាយុវណ្ណៈ សុខៈ ពលៈ យសស័ក្តិ សួគ៌ និងអធិបតេយ្យភាពប្រព្រឹត្តទៅ គឺនាយចុន្ទបានសាងទុកហើយ ; ម្នាលអានន្ទ ! វិប្បដិសារីសេចក្តីក្តៅក្រហាយរបស់នាយចុន្ទកម្មារបុត្រ លោកទាំងឡាយគប្បី

ស្តាប់ឲ្យបានស្ងប់ដោយគាថាគតសុភាសិត" នេះចុះ ។

## ព្រះបន្ទំអនុដ្ឋានសេយ្យា

គ្រានោះព្រះមានព្រះភាគព្រមទាំងភិក្ខុសង្ឃជាច្រើន ទ្រង់ស្តេចយាងឆ្លងស្ទឹងហិរញ្ញវតីដល់នគរកុសិនារា ហើយទ្រង់ស្តេចយាងចូលទៅសំណាក់ក្នុងព្រៃសាលវ័ន ទ្រង់ត្រាស់ពុទ្ធបញ្ជាដល់ព្រះអានន្ទថា "ម្នាលអានន្ទ ! ចូរអ្នករៀបចំគ្រែឲ្យមានក្បាលដំណេកបែរទៅខាងឧត្តរទិសក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូឲ្យតថាគតដោយឆាប់ តថាគតហត់នឿយណាស់ តថាគតនឹងសិងរម្ងាប់សេចក្តីលំបាក" ។ ព្រះអានន្ទថេរបានទទួលពុទ្ធាណត្តិដោយគោរពហើយ ក៏រៀបតែងតាំងនូវគ្រែទន ព្រះបន្ទំបរិនិព្វានសេយ្យាក្នុងចន្លោះនៃដើមសាលព្រឹក្សទាំងគូ គ្រានោះព្រះមានព្រះភាគស្តេចទ្រង់សម្រេចនូវសីហសេយ្យាមានសតិ និង សម្បជញ្ញៈតែមិនបានធ្វើទុកក្នុងព្រះហឫទ័យនូវឧដ្ឋានសញ្ញា ព្រោះជាសេយ្យាវសាន ហៅថាអនុដ្ឋានសេយ្យា ។

## ប្រារព្ធសក្ការបូជា
## ទ្រង់ប្រកបពុទ្ធបរិស័ទក្នុងសម្មាបដិបត្តិ

តេន ខោ បន សមយេន យមកសាលា សព្វផាលិផុល្លា ហោន្តិ

ក្នុងសម័យនោះ ដើមសាលព្រឹក្សទាំងគូបានបញ្ចេញផ្កាផ្លែខុសរដូវកាល ពាសពេញព្រឹក្សមណ្ឌល តាំងពីគល់ដល់ចុង ដេរដាសទៅដោយផ្កាគួរអស្ចារ្យណាស់ ។ សាលព្រឹក្សទាំងនោះជម្រុះផ្កាធ្លាក់ចុះមករោយរាយក្នុងទីជុំវិញព្រះពុទ្ធសរីរៈ ដើម្បីបូជាព្រះតថាគត ។ សូម្បីផ្កាមន្ទារវព្រឹក្សនឹងលំអិតនៃខចន្ទន៍សុគន្ធជាតិ ដែលសុទ្ធតែជារបស់ទិព្វ មានក្លិនក្រអូបឈ្ងុយឈ្ងប់ ក៏ធ្លាក់ចុះអំពីអាកាសវេហាស៍មកបូជាព្រះតថាគត ពាសពេញទាំងសាលវនោទ្យាន ឯទាំងតន្ត្រីទិព្វរបស់ទេវតាទាំងឡាយ ក៏បន្លឺសំឡេងឡើងរងំប្រគំលាន់ឮកងរំពង មហានាទទៅឯអាកាសវេហាស៍ ដើម្បីបូជាព្រះឧត្តមមុនីសាស្តាចារ្យសម្មាសម្ពុទ្ធក្នុងអវសានកាល ។ លំដាប់នោះ សម្តេចព្រះបរមនាថ ទ្រង់ប្រកបដោយទិព្វចក្ខុញាណ ទិព្វសោតញាណដោយវិសេស ត្រាស់ហៅព្រះអានន្ទត្ថេរមកទ្រង់សំដែងអំពីវត្ថុ ដែលជាសក្ការបូជាដ៏ជាទិព្វដល់ព្រះអានន្ទ ហើយទ្រង់សំដែងនូវការបូជា ចំពោះព្រះតថាគតដោយអាមិសដ៏ច្រើន ដែលចាត់ចូលបូជាហើយមិនឈ្មោះថា បូជាចំពោះព្រះតថាគតទេព្រះអានន្ទថា "យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្ម

តាវ សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជា ” ។

“ ម្នាលអានន្ទ! បុគ្គលណាមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី បុគ្គលនោះឈ្មោះថាធ្វើសក្ការៈ ធ្វើសេចក្តីគោរព រាប់អានបូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម ” ម្នាលអានន្ទ! ព្រោះហេតុនោះ ភិក្ខុទាំងឡាយដែលជាសាវកតាំងខ្លួនថា “ យើងទាំងឡាយនឹងជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរ ” ដូច្នេះ ម្នាលអានន្ទ! លោកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។ សម្តេចព្រះសម្ពុទ្ធបរមគ្រូ ជាធម្មិស្សរាធិបតី ទ្រង់ប្រកបសាវកពុទ្ធបរិស័ទក្នុងធម្មានុធម្មប្បដិបត្តិ សឹងមានពុទ្ធបំណង នឹងឲ្យព្រះពុទ្ធសាសនាតាំងនៅជាស្ថាពរបានដោយប្រការដូច្នេះ ។

## ទ្រង់សំដែងការប្រព្រឹត្តទៅនៃទេវតា

តេន ខោ បន សមយេន សម័យនោះ ព្រះឧបវាណត្ថេរ ដ៏មានអាយុ លោកកំពុងឈរថ្វាយវីជនី ( បក់ផ្លិត ) ក្នុងទីចំពោះព្រះភក្ត្រ

ព្រះមានព្រះភាគ ព្រះអង្គទ្រង់ដេញឧបវាណត្ថេរដ៏មានអាយុនោះថា អបេហិ ភិក្ខុ ម្នាលភិក្ខុអ្នកចូរចៀសចេញ លោកកុំឈរនៅពីមុខតថាគត ” ។

គ្រានោះព្រះអានន្ទក៏គិតរិះគន់ថា “ព្រះឧបវាណៈដ៏មានអាយុអង្គនេះ ជាអ្នកឧបដ្ឋាកព្រះមានព្រះភាគយ៉ាំងជិតស្និទ្ធមកយូរហើយ ដល់កាលចុងបំផុត ព្រះមានព្រះភាគជាម្ចាស់ទ្រង់មិនជ្រះថ្លាដេញលោកឲ្យចៀសចេញទៅ មិនឲ្យឈរនៅក្នុងទីចំពោះព្រះភក្ត្រ រឿងនេះព្រោះហេតុអ្វីហ្ន៎? ” ព្រះអានន្ទគិតដូច្នោះហើយក្រាបទូលសួរ ។ ព្រះមានព្រះភាគទ្រង់សំដែងហេតុថា “យេភុយ្យេន អានន្ទ ម្នាលអានន្ទទេវតាទាំងឡាយក្នុងម៉ឺនលោកធាតុមកប្រជុំគ្នាហើយដោយច្រើន ដើម្បីនឹងបានឃើញព្រះមានព្រះភាគ, ម្នាលអានន្ទ! នគរកុសិនារា សាលវនោទ្យានមានទំហំ ១២ យោជន៍ដោយជុំវិញ ឥតមានចន្លោះសល់ទំនេរ សូម្បីប៉ុនរោមសត្វព្រាយឡើយ ជាទីពេញព្រៀបណែនណាន់តាន់តាប់ដោយទេវតាដែលមានសក្តាធំទាំងឡាយ, ម្នាលអានន្ទ! ទេវតាទាំងឡាយនឹងលើកទោសថា “យើងទាំងឡាយបានមកហើយអំពីចម្ងាយ ចំណាំនឹងឃើញព្រះតថាគត កទាចិ ករហចិ តថាគតា ព្រះតថាគត

សត្វមនុស្សទាំងឡាយ តែងឧប្បត្តិឡើងក្នុងលោកក្នុងកាលខ្លះ ។ (យូរ
កាលវេលាណាស់) ទើបមានម្តង ។

អដ្ឋ រត្តិយា បច្ឆិមេ យាមេ ការបរិនិព្វានរបស់ព្រះតថាគត.ជា
ម្ចាស់នឹងមានក្នុងបច្ឆិមយាមនៃពេលយប់ថ្ងៃនេះហើយ អយញ្ច មហេសក្ខោ
ភិក្ខុ តែភិក្ខុមានសក្តិធំអង្គនេះ មកឈរបាំងព្រះភក្ត្រនៃព្រះមានព្រះភាគ
ន មយំ លភាម យើងទាំងឡាយមិនបានឃើញព្រះមានព្រះភាគ
ក្នុងកាលចុងបំផុតនេះ ទេវតាទាំងឡាយលើកទោសយ៉ាងនេះ ទើបយើង
ចេញឧប្បវណកិច្ចឲ្យជៀសចេញពីមុខដោយប្រការដូច្នេះ ។

ព្រះអានន្ទទើបក្រាបទូលសួរអំពីប្រវត្តិនៃទេវតាថា "ភន្តេ បន
ភន្តេ ទេវតា បពិត្រព្រះមានព្រះភាគ ចុះទេវតាទាំងឡាយតើដូចម្តេច
បានធ្វើទុកក្នុងចិត្តដោយប្រការដូចម្តេចទៅ ?" ព្រះមានព្រះភាគទ្រង់
ត្រាស់តបថា "សត្ថានន្ទទេវតា ទេវតាទាំងឡាយមានសេចក្តីសំ
គាល់ថៃល្ហាស់ក្នុងអាកាសជាដាប់ប្រថពី ក្ដូម៉េទេវតាទាំងឡាយ សំគាល់នូវ
ផែនដីជាផែនដី(១)ដូច្នេះ ហើយក៏គាំងរំសាយសក់លើកដៃទាំងពីរ
ទះនៀលទៅមកដួចជាមានជើងដាច់ សង្រេងសង្រែចំពោះព្រះមានព្រះ

១ តាមបាលីដើមដូច្នេះឯង តែគួរសំគាល់ខុសថាជា "អាកាស" ដូច្នោះវិញ

អតិខិប្បំ ភគវា បរិនិព្វាយិស្សតិ ព្រះមានព្រះភាគទ្រង់បរិនិព្វានឆាប់ហ័សណាស់ អតិខិប្បំ សុគតោ បរិនិព្វាយិស្សតិ ព្រះសុគតជាម្ចាស់ទ្រង់បរិនិព្វានឆាប់ហ័សណាស់ អតិខិប្បំ ចក្ខុំ លោកេ អន្តរធាយិស្សតិ ផ្លូវចក្ខុក្នុងលោកនឹងអន្តរធានឆាប់ហ័សណាស់ ៗ យា បន តា ទេវតា ចំណែកទេវតាទាំងឡាយណាដែលមានរាគៈទៅប្រាសហើយ គឺជាអនាគាមីនិងព្រះអរហន្ត សតា សម្បជានា ទេវតាទាំងនោះមានសតិសម្បជញ្ញៈអត់សង្កត់ដោយធម្មសង្វេគថា អនិច្ចា សង្ខារា សង្ខារធម៌ដែលបច្ច័យប្រជុំតាក់តែងទាំងឡាយមិនទៀង តំ កុតេត្ថ លព្ភា របស់ទៀងដែលសត្វទាំងឡាយប្រាថ្នាណាស់នោះ សត្វទាំងឡាយមិនគប្បីបានក្នុងសង្ខារទាំងឡាយនេះឡើយៗ ព្រះមានព្រះភាគទ្រង់ព្រះសំដែងប្រវត្តិ នៃទេវតាទាំងឡាយដែលមកប្រជុំក្នុងគ្រានោះដល់ព្រះអានន្ទដោយប្រការដូច្នោះ ៗ

## ទ្រង់សំដែងសង្វេជនីយដ្ឋាន ៤

គ្រានោះ ព្រះអានន្ទត្ថេរក្រាបទូលសួរថា "បុព្វេ ភន្តេ ទិសាសុ វស្សំ វុត្ថា ភិក្ខូ" បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលមុន ភិក្ខុទាំងឡាយដែលចាំវស្សាក្នុងទិសផ្សេង ៗ គ្រប់កំណត់ត្រៃមាស តាមវិនយានុញ្ញាតហើយ

តែងចូលមកគាល់ព្រះតថាគតដោយអាចិណ្ណវត្ត ខ្ញុំព្រះអង្គទាំងឡាយក៏
បានឃើញព្រមទាំងចូលទៅអង្គុយជិតភិក្ខុទាំងឡាយនោះ ដែលឲ្យ
ចំរើនចិត្ត ។ កាលណាបើអំណោះផុតអំពីព្រះអង្គទៅហើយ ខ្ញុំព្រះអង្គ
ទាំងឡាយនឹងមិនបានឃើញ មិនបានចូលទៅអង្គុយជិតសាកច្ឆាជាមួយ
នឹងភិក្ខុទាំងឡាយដែលឲ្យចំរើនចិត្ត ដូចកាលព្រះអង្គគង់ធរមាននៅនោះ
ឡើយ ។ ឯវំ វុត្តេ កាលព្រះអានន្ទក្រាបទូលយ៉ាងនេះហើយ ព្រះបរម
លោកនាថទ្រង់សំដែង សំវេជនីយស្ថានទាំង ៤ ជាស្ថានដែលគួរឃើញ
គួរឲ្យកើតសំវេគនៃកុលបុត្រដែលមានសទ្ធាជ្រះថ្លា គឺទីដែលព្រះតថាគត
ទ្រង់ប្រសូតចាកព្រះឧទរ ១, ទីដែលព្រះតថាគតទ្រង់ត្រាស់ដឹងអនុត្តរ
សម្មាសម្ពោធិញ្ញាណ ១, ទីដែលព្រះតថាគតទ្រង់ញុំាងអនុត្តរធម្មចក្រឲ្យ
ប្រព្រឹត្តទៅ ១, ទីដែលព្រះតថាគតទ្រង់បរិនិព្វានដោយអនុបាទិសេស
និព្វានធាតុ ១ ទីទាំង ៤ នេះ ជាទីគួរមើលឃើញគួរឲ្យកើតសេចក្តី
សង្វេគ របស់កុលបុត្រអ្នកមានសទ្ធា ។ អាគមិស្សន្តិ ខោ អានន្ទ
ម្នាលអានន្ទ ! ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលមានសទ្ធា
នឹងមកកាន់ទីតាំង ៤ ស្ថាននោះដោយសេចក្តីជឿថា ព្រះតថាគតទ្រង់
ប្រសូតក្នុងទីនេះ ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះ

ញាំងឲ្យអនុត្តរធម្មចក្រប្រព្រឹត្តទៅ ហើយក្នុងទីនេះ ព្រះអង្គស្តេចបរិ-និព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ៗ យេ ហិ កេចិ អានន្ទ ម្នាលអានន្ទ ជនទាំងឡាយណាមួយត្រាច់ទៅកាន់ចេតិយចារិក ជាអ្នកមានសេចក្តីជ្រះថ្លាធ្វើកាលកិរិយាក្ស័យ សុគតិំ សគ្គំ លោកំ ឧបបជ្ជិស្សន្តិ ជនទាំងនោះនឹងទៅកើតក្នុងសុគតិភព ៗ សម្តេចព្រះមានព្រះភាគជាម្ចាស់ទ្រង់សំដែងសាន្ទនីយស្ថានទាំង ៤ ដោយប្រ-ការដូច្នេះឯង ៗ

## អាការដែលភិក្ខុទាំងឡាយគប្បីប្រតិបត្តិក្នុងស្ត្រីភាព

លំដាប់នោះ ព្រះអានន្ទក្រាបទូលសួរចំពោះព្រះមានព្រះភាគនូវការប្រតិបត្តិក្នុងស្ត្រីភាពទាំងឡាយថា កថំ មយំ ភន្តេ មាតុគាមេ បដិបជ្ជាម បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយនឹងប្រតិបត្តិដូចម្តេច ចំពោះមាតុគ្រាម ? អទស្សនំ អានន្ទ ម្នាលអានន្ទ ! ការមិនមើលជាការប្រតិបត្តិក្នុងមាតុគ្រាម គឺជាកុំមើលជាការល្អ ៗ ទស្សនេ ភគវា សតិ បពិត្រព្រះមានព្រះភាគ ចុះបើការមើលបានកើតមានឡើង តើឲ្យខ្ញុំព្រះអង្គប្រតិបត្តិដូចម្តេច? អនាលាបោ អានន្ទ ម្នាលអានន្ទ ! បើឃើញហើយការមិនចរចាជាការប្រតិបត្តិសមគួរ ៗ អាលបន្តេ បន

ភន្តេ កាលបើការបូជាកើតមានឡើង តើខ្ញុំព្រះអង្គត្រូវប្រតិបត្តិដូចម្តេចទៀត ? សត្ថា អានន្ទ ឧបដ្ឋាកព្វា ម្នាលអានន្ទ ! បើប្រយោជន៍ដែលត្រូវបូជាដោយអំណាចធម្មកថាជាដើមមាន · សត្ថាសេចក្តីលើកដែលលោកទាំងឡាយគប្បីតាំងទុកក្នុងចិត្តឲ្យជាប់ លោកទាំងឡាយគប្បីតាំងសតិទុកកុំឲ្យវិប្រប្រួលដោយកតតណ្ហា ទាំងអាការកាយវាចាកុំឲ្យល្មើសអំពីវាចាជារបស់សមណៈបាន ។

ទ្រង់ប្រៀនប្រដៅក្នុងការដែលត្រូវប្រតិបត្តិក្នុងស្ត្រីភាព ដោយប្រការដូច្នេះ ។

## វិធីប្រតិបត្តិក្នុងពុទ្ធសរីរៈ

លំដាប់នោះ ព្រះអានន្ទត្ថេរបានក្រាបទូលសួរអំពីការដែលគួរប្រតិបត្តិក្នុងព្រះពុទ្ធសរីរៈ របស់ព្រះអង្គបរមលោកគ្រូមានពាក្យជាម្ចាស់ថា កថំ មយំ ភន្តេ តថាគតស្ស សរីរេ បដិបជ្ជាម បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយនឹងគប្បីប្រតិបត្តិដូចម្តេច ក្នុងពុទ្ធសរីរៈនៃព្រះតថាគត អព្យាវដា តុម្ហេ អានន្ទ ហោថ តថាគតស្ស សរីរបូជាយ ម្នាលអានន្ទ យើងតឿនអ្នកទាំងឡាយ ។ ចូរបន្តុអនុយោគព្យាយាមក្នុងប្រយោជន៍របស់ខ្លួនចុះ សទត្ថេ អប្បមត្តា លោកទាំងឡាយចូរជាអ្នក

មិនប្រមាទក្នុងប្រយោជន៍របស់ខ្លួន ចូរជាបុគ្គលអ្នកមានសេចក្ដីព្យាយាម
ជាគ្រឿងញុំាងកិលេសនិងបាបធម៌ឲ្យក្ដៅសព្វ ជាអ្នកមានខ្លួនបញ្ជូនទៅ
ហើយ ចុះបើងចំពោះទីបំផុតនៃព្រហ្មចរិយធម៌គ្រប់ឥរិយាបថបួន ៗ
សព្ទានន្ទ ម្នាលអានន្ទ ក្សត្រព្រាហ្មណ៍និងគហបតីជាបណ្ឌិតទាំងឡាយ
ដែលបានញុំាងចិត្តឲ្យជ្រះថ្លាចំពោះព្រះតថាគតមានច្រើន គ្រហស្ថជា
បណ្ឌិតទាំងឡាយមានក្សត្រជាដើមនោះ នឹងធ្វើនូវសក្ការៈបូជានូវសរីរៈ
នៃព្រះតថាគត ។ កាលព្រះអង្គទ្រង់ត្រាស់ថា "ការបូជាព្រះពុទ្ធសរីរៈជា
កិច្ចរបស់គ្រហស្ថមានក្សត្រជាដើមដូច្នោះហើយ" លុះគ្រាសម័យព្រះអង្គ
ទ្រង់បរិនិព្វាន ក្សត្រព្រាហ្មណ៍និងគហបតីជាបណ្ឌិតទាំងឡាយនឹងធ្វើនូវ
ការបូជាព្រះសរីរៈ ឲ្យត្រឹមត្រូវតាមពុទ្ធាធិប្បាយ គប្បីសួរព្រះអានន្ទជា
អគ្គពហុស្សុតពុទ្ធុបដ្ឋាក កាលបើដូច្នោះនឹងពោលអានថា កិច្ចនេះព្រះ
ពុទ្ធព្រះអង្គទ្រង់ត្រាស់ថា មិនមែនជាការកិច្ចរបស់សហធម្មិកបព្វជិត បាន
ជាយើងមិនក្រាបទូលសួរដូច្នេះ ក៏មិនមែនជាការសមគួរដល់បណ្ឌិតអ្នក
កាន់ទៅក្នុងអំណាចនៃហេតុឡើយគួរនឹងក្រាបទូលសួរទុកជាខេត្តបទដ្ឋាន
ទើបជាការសមគួរ កាលបើបានក្រាបទូលសួររួចហើយ តែព្រះអង្គមិន
ទ្រង់សំដែង នោះជាការងាយដោះស្រាយដោយពោលអានថា បាន

ក្រាបទូលសួរហើយ តែព្រះអង្គមិនទ្រង់បរិយាយ ដូច្នេះទើបជាការប្រពៃ មិនកើតពាក្យគរហាអំពីអ្នកដទៃ ,  កាលបើទូលសួរហើយព្រះអង្គទ្រង់សំដែងយ៉ាងណា ក៏គួរចាំទុកយ៉ាងនោះ កាលបណ្ឌិតមានក្សត្រជាដើមមកសាកសួរនឹងបានសំដែងតាមពុទ្ធាធិប្បាយ តស្លូ ព្រោះហេតុនោះ ទើបព្រះអានន្ទលោកមានឧត្តមគតិក្រាបទូលសួរថា កថម្បន ភន្តេ បពិត្រព្រះអង្គដ៏ចំរើនចុះកាលបើបណ្ឌិតមានក្សត្រជាដើមមកសួរថា តើនឹងគប្បីប្រតិបត្តិក្នុងព្រះពុទ្ធសរីរៈព្រះតថាគតដូចម្តេច? យថា ខោ អានន្ទ ម្នាលអានន្ទ ជនទាំងឡាយតែងប្រតិបត្តិក្នុងសរីរៈនៃស្តេចចក្រពត្តិបែបណា អ្នកដែលបូជាព្រះសរីរៈព្រះតថាគតក៏គប្បីប្រតិបត្តិបែបនោះចុះ ។ កថំ បន ភន្តេ បពិត្រព្រះមានព្រះភាគ ជនទាំងឡាយតែងប្រតិបត្តិក្នុងសរីរៈរបស់ព្រះចៅចក្រពត្តិដូចម្តេច? រញ្ញោ អានន្ទ ចក្កវត្តិស្ស ម្នាលអានន្ទ ជនទាំងឡាយរុំរូវសរីរៈរបស់ព្រះចៅចក្រពត្តិកដោយសំពត់ថ្មី (មួយជាន់ ហើយព្រាប់ដោយសំឡី រុំដោយសំពត់ថ្មីទៀត តាមរបៀបនេះអស់សំពត់៥០០គូ) ។ អយសាយ តេលទោណិយា បក្ខិបិត្វា រួចហើយទើបអញ្ជើញព្រះសរីរៈទៅប្រតិស្ថានក្នុងស្រោនដែកដ៏ពេញដោយប្រេងហើយបិទគំរបដែក ។ ធ្វើចិត-កាគារ ដោយឈើដែលមានក្លិនក្រអូប ។ ធ្វើឈាបនកិច្ចថ្វាយព្រះភ្លើង

ព្រះសរីរៈព្រះចៅចក្រពត្តិស្រេចហើយ ទើបអញ្ជើញព្រះអដ្ឋិធាតុទៅ
បញ្ចុះក្នុងព្រះស្តូប ៗ ព្រះស្តូបនោះត្រូវធ្វើក្នុងទីប្រជុំនៃថ្នល់ធំទាំងបួន ៗ
ជនទាំងឡាយតែងប្រតិបត្តិក្នុងសរីរៈ នៃព្រះចៅចក្រពត្តិកដោយប្រការ
ដូច្នេះ អ្នកដែលបូជាព្រះសរីរៈនៃព្រះតថាគតក៏គប្បីប្រតិបត្តិតាមបែបដូច
ជាព្រះចៅចក្រពត្តិនោះចុះ ៗ ចាតុម្មហាបថេ តថាគតស្ស ថូបោ កាតព្វោ
គប្បីធ្វើស្តូបនៃព្រះតថាគតក្នុងទីជាទីប្រជុំមហាវិថីទាំងបួន ដើម្បីជាទី
ធ្វើនូវសក្ការបូជានៃមនុស្សនិករដែលសញ្ចរមកពីទិសទាំងបួន ឲ្យកើត
សេចក្តីជ្រះថ្លា ក្នុងចិត្តសន្សំនូវអនុស្សរានុត្តរិយកុសលនឹងបូជាមយបុញ្ញ
កម្ម ៗ តត្ថ យេ មាលំ វា គន្ធំ វា វណ្ណកំ វា អារោបេស្សន្តិ
ជនទាំងឡាយណានឹងលើកឡើងនូវកម្រងផ្កា ឬសុគន្ធជាតិឬក៏នូវលំអិត
បូជាព្រះស្តូបនោះក្តី អភិវាទេស្សន្តិ វា អភិវាទនមស្ការនូវព្រះស្តូប
នោះជានិច្ចកាលក្តី ចិត្តំ វា បសាទេស្សន្តិ ញុំាងចិត្តឲ្យជ្រះថ្លា
ក្នុងព្រះពុទ្ធគុណព្រោះឃើញព្រះស្តូបនោះក្តី តេសន្តំ ភវិស្សតិ
ទីឃរត្តំ ហិតាយ សុខាយ កិច្ចទាំងអស់នោះសុទ្ធតែប្រព្រឹត្តទៅដើម្បីប្រ
យោជន៍ ដើម្បីសេចក្តីសុខដល់ជនទាំងឡាយអស់កាលជាយូរ ៗ ឯវំ
ទេសេត្វា សម្តេចព្រះភគវន្តមុនី ទ្រង់ត្រាស់សំដែងអំពីវិធីប្រតិបត្តិក្នុង

ព្រះពុទ្ធសរីរៈ របស់ព្រះតថាគតនឹងស្តេចចក្រពត្តិរាជ ដែលជាអច្ឆរិយ បុរសរតន៍ ជាថូបារហបុគ្គល គឺជាបុគ្គលគួរដល់ការដំកល់ទុកក្នុងព្រះស្តូបដូច្នេះហើយទើបទ្រង់សំដែងថូបារហបុគ្គលដោយពិស្តារ គឺព្រះសម្មាសម្ពុទ្ធបរមគ្រូ១, ព្រះបច្ចេកពុទ្ធ១, ព្រះអរហន្តសាវក១, ព្រះចៅចក្រពត្តិ១ ។

បុគ្គលពិសេសទាំង៤នេះ ជាថូបារហបុគ្គលគួរដល់ព្រះស្តូបគឺគួរដំកល់ព្រះអដ្ឋិធាតុទុកជាទីសក្ការបូជាដោយសេចក្តីជ្រះថ្លា ក៏អាចជាជនកបច្ច័យនាំសត្វឲ្យកើតក្នុងសុគតិភព កាមគួរដល់បសាទចិត្តដែលប្រព្រឹត្តទៅក្នុងស្តូបនៃថូបារហបុគ្គលទាំង ៤ នេះ ។ សម្តេចព្រះមានព្រះភាគទ្រង់សំដែងថូបារហបុគ្គលដល់ព្រះអានន្ទត្ថេរ ដោយប្រការដូច្នោះឯង ។

## ទ្រង់ប្រទានឱវាទដល់ព្រះអានន្ទ

អថ ខោ អាយស្មា អានន្ទោ គ្រានោះព្រះអានន្ទមានអាយុចូលទៅក្នុងព្រះវិហារកបិសីសៈ(១) ឈរសោយសោកពោលថា អហញ្ហិ សេខោ សករណីយោ អាត្មាអញជាសេខបុគ្គលមានកិច្ចដែលត្រូវធ្វើមិនទាន់សម្រេចនៅឡើយ , ព្រះសាស្តាអង្គណាដែលទ្រង់អនុគ្រោះដល់

---

១ ខ្ពួសម្ភារ :មានសណ្ឋានដូចក្បាលស្វា

អាត្មាអញ ព្រះសាស្ដាអង្គនោះទ្រង់បរិនិព្វានទៅហើយ » គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក សួររកព្រះអានន្ទ ៗ ភិក្ខុទាំងឡាយក្រាបទូលថា « អានន្ទចូលទៅក្នុងវិហារឈរយំសោកក្នុងទីនោះ » ទើបទ្រង់ត្រាស់ឲ្យហៅអានន្ទឲ្យចូលមកគាល់ ៗ លុះអានន្ទចូលទៅក្រាបបង្គំគាល់ ព្រះអង្គទ្រង់ត្រាស់ថា អលំ អានន្ទ ម្នាលអានន្ទ! កុំ! លោកកុំយំសោក, កុំខ្សឹកខ្សួល យើងតថាគតប្រាប់ហើយនេះតាំងពីដើមថា ការប្រព្រឹត្តិទៅផ្សេងៗ,ការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ជាទីពេញចិត្តទាំងពួងនោះ ឥតមានទំនេរ ម្នាលអានន្ទ! ថាវត្ថុ ដែលសត្វប្រាថ្នាណាស់នោះ សត្វទាំងឡាយមិនគប្បីបាន(សមតាមបំណង)ក្នុងសង្ខារនេះឡើយ របស់ណាដែលកើតមានឡើង ដែលបច្ច័យតាក់តែងឲ្យកើតឡើង រមែងវិនាសទៅជាធម្មតា» បុគ្គលណានឹងប្រាថ្នាថា « សូមរបស់នោះកុំវិនាសទៅឡើយដូច្នេះ, សេចក្ដីប្រាថ្នារបស់បុគ្គលនោះមិនសម្រេចឡើយ ៗ ម្នាលអានន្ទលោកបានឧបដ្ឋាកតថាគតដោយកាយកម្មវចីកម្មនឹងមនោកម្មដែលប្រកបដោយមេត្តាគ្មាន ២ មិនមានប្រមាណ មកអស់កាលយូរយារណាស់ហើយ លោកជាបុគ្គលមានបុណ្យបានធ្វើហើយ លោកចូរប្រកបសេចក្ដីព្យា

យាមលោកនឹងជាអ្នកមិនមានអាសវៈដោយឆាប់ គឺនឹងបានសម្រេចព្រះអរហត្តដោយឆាប់មិនខាន ។ សម្ដេចព្រះមានព្រះភាគទ្រង់ត្រាស់ព្យាករណ៍ព្រះអានន្ទដោយប្រការដូច្នេះ ។

## ត្រាស់សរសើរព្រះអានន្ទ

អថ ខោ ភគវា លំដាប់នោះ សម្ដេចព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ទ្រង់សរសើរនូវព្រះអានន្ទជាពុទ្ធុបដ្ឋាកយ៉ាងក្រៃលែងថា "ម្នាលភិក្ខុទាំងឡាយ អង្គព្រះសម្មាសម្ពុទ្ធទាំងឡាយណាដែលមានក្នុងអតីត ភិក្ខុដែលជាពុទ្ធុបដ្ឋាកយ៉ាងក្រៃលែងរបស់ព្រះពុទ្ធទាំងឡាយអង្គនោះ ក៏ដូចគ្នានឹងអានន្ទជាឧបដ្ឋាករបស់តថាគតក្នុងកាលឥឡូវនេះដែរ ។ សូម្បីព្រះអរហំសម្មាសម្ពុទ្ធទាំងឡាយអង្គណា ដែលនឹងមានក្នុងអនាគតកាល ភិក្ខុជាពុទ្ធុបដ្ឋាកយ៉ាងក្រៃលែងរបស់ព្រះពុទ្ធទាំងឡាយអង្គនោះ ក៏ដូចគ្នានឹងអានន្ទជាឧបដ្ឋាករបស់តថាគតក្នុងកាលឥឡូវនេះដែរ ម្នាលភិក្ខុទាំងឡាយ អានន្ទជាបណ្ឌិត ជាអ្នកមានប្រាជ្ញាតែងដឹងច្បាស់ថា » នេះជាកាលគួរដើម្បីឲ្យបរិស័ទចូលគាល់ព្រះតថាគត នេះជាកាលនៃភិក្ខុ នេះជាកាលនៃភិក្ខុនី នេះជាកាលនៃឧបាសក នេះជាកាលនៃឧបាសិកា នេះជាកាលនៃព្រះរាជ

មហាក្សត្រ នេះជាកាលនៃមហាមាត្យ នេះជាកាលនៃគ្រិយ នេះជាកាលនៃសាវកគ្រិយ, អានន្ទនែងដឹងនូវកាលដែលបរិស័ទទាំង ៤ នឹងព្រះកជា កជមហាមាត្យ គ្រិយសាវករបស់គ្រិយ ចូលគាល់តថាគតគ្រប់ប្រការដូច្នេះ ។ តមកព្រះអង្គទ្រង់សំដែងសេចក្តីអស្ចារ្យ ៤ ប្រការដែលមានក្នុងព្រះអានន្ទដោយពិស្តារ កាលណាបើបរិស័ទទាំង ៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ចូលទៅជិតដើម្បីឃើញព្រះអានន្ទ បរិស័ទនោះគ្រាន់តែបានឃើញព្រះអានន្ទហើយក៏មានចិត្តជ្រះថ្លា បើអានន្ទសំដែងធម៌ទេសនា បរិស័ទនោះក៏មានចិត្តត្រេកអររីករាយទៅដោយសុភាសិតរបស់អានន្ទមិនឆ្អែតមិននឿយណាយដោយសុភាសិតរបស់អានន្ទឡើយ កាលបើអានន្ទបញ្ចប់ធម្មកថា បរិស័ទទាំង ៤ ដែលបានស្តាប់នោះក៏មានចិត្តត្រេកអរទាំងមិនឆ្អែតឆ្អន់មិននឿយណាយ ដូចជាស្តេចចក្រពត្តិដែលញុំាងក្សត្រ ព្រាហ្មណ៍ គហបតី សមណបរិស័ទឲ្យត្រេកអរដូច្នោះ ។

## ទ្រង់ត្រាស់អំពីនគរកុសិនារា

ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កាលព្រះមានព្រះភាគទ្រង់សរសើរព្រះអានន្ទដោយប្រការដូច្នេះហើយ ព្រះអានន្ទដ៏មានអាយុក៏ក្រាបទូលអារាធនាព្រះមានព្រះភាគឲ្យស្តេចយាងទៅបរិនិព្វាន

ឯនគរដទៃទៀតជា មា ភន្តេ ភគវា ឥមស្មឹ ខុទ្ទកនគរកេ ឧជ្ជង្គលនគរកេ សាខនគរកេ បរិនិព្វាយ បពិត្រព្រះមានព្រះភាគ សូមព្រះមានព្រះភាគ កុំស្តេចបរិនិព្វានក្នុងស្រុកតូចជាស្រុកចុងកាត់មាត់ញកយើងនេះឡើយ សន្តិ ភន្តេ ព្រះមហានគរធំ ៗ ដទៃមានច្រើន គឺចម្បា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី ពារាណសី សុទ្ធតែជានគរធំ ៗ សូមព្រះអង្គស្តេចបរិនិព្វានក្នុងនគរនោះចុះ ក្សត្រ ព្រាហ្មណ៍ គហបតីមហាសាលដែលជ្រះថ្លាចំពោះព្រះតថាគតក៏មានច្រើនក្នុងមហានគរនោះ នឹងបានធ្វើនូវការបូជា ព្រះពុទ្ធសរីរៈ នៃព្រះតថាគតជាមហោឡារតួរដល់សក្ការព្រះសម្មាសម្ពុទ្ធ ដែលជាអនាគារិកបុរសរតនអច្ឆរិយមនុស្សក្នុងលោក។ ព្រះមានព្រះភាគទ្រង់ត្រាស់ហាមអានន្ទ ថា " ម្នាលអានន្ទ ! កុំពោលថានគរកុសិនារា ជានគរតូចជានគរចុងកាត់មាត់ញកជាចុងនគរយើងនេះ ។ កាលសម័យមុនមានព្រះចៅចក្រពត្តិរាជ ព្រះនាមសុទស្សនៈ ទ្រង់ជាស្រ្តាធិបតីក្នុងបរិមណ្ឌលមានមហាសមុទ្រទាំង ៤ ជាព្រំខណ្ឌសីមា ព្រះអង្គទ្រង់ឈ្នះនូវបច្ចាមិត្តដោយធម៌ ដោយឥតមានប្រើទណ្ឌឬសស្ត្រាឡើយ ព្រះអង្គមានជនបទតាំងមាំដែលសត្រូវមិនអាចប្រទូសរ៉ាយបាន ព្រះអង្គប្រកបដោយរតនៈ ជាវត្ថុនាំឲ្យកើតសេចក្តីត្រេកអរគឺកែវ៧ប្រការ

នគរកុសិនារានុះ ជារាជធានីមួយឈ្មោះកុសាវតី ជាទីស្ដេចប្រថាប់នៅនៃព្រះបាទមហាសុទស្សនៈចក្រពត្តិរាជ. ជានគរទូលាយ ដោយប្រវែងខាងទិសបូព៌ានិងទិសបស្ចិម ១៦ យោជន៍ ដោយទទឹងខាងឧត្តរនិងទក្សិណ ៧ យោជន៍ ។ នគរកុសាវតីជារាជធានីសម្បូណ៌ហូរហៀរ មានប្រជាជន ច្រើនកុះករ កកកុញ បរិបូណ៌ដោយ ភិក្ខាហារ ជារមណីយដ្ឋាន គួររីករាយចិត្តដូចអាលកមន្ទា រាជធានីទេព្តានៅឋានស្ថានទេវលោកជាន់ចាតុម្មហារាជិកាដូច្នោះ ។ នគរកុសាវតីជាទីគឹកកងរំពងតាំងយប់តាំងថ្ងៃដោយសំឡេងទាំង ១០ គឺ សម្លេងគជសា ១ អស្ស-ពាជី ១, រថ ១, ស្គរ ១, សំភោរ ១, ពិណ ១, ចំរៀង ១, កំសតាល ១, សំឡេងសាំង ១ ទាំងសំឡេងប្រជាជនគោករហៅគ្នាបរិភោគអាហារ ១ ត្រូវជា ១០ ឥតមានពេលស្ងៀមស្ងាត់ក្នុងទិវារាត្រីណាមួយឡើយ ។

## ទ្រង់ពុទ្ធបញ្ជាឲ្យអានន្ទឲ្យដំណឹងនិព្វានដល់ពួកមល្លក្សត្រ

ឯវំ មេ សុត្វា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សំដែងអំពីប្រវត្តិសង្ខេប នៃនគរកុសនារាជារាជធានីធំរបស់ព្រះចៅមហាសុទស្សនចក្រពត្តិរាជតាំងពីអតីតកាលឲ្យអានន្ទបានដឹងហើយ តមកទ្រង់បញ្ជាឲ្យអានន្ទនាំដំណឹងពុទ្ធបរិនិព្វានទៅប្រាប់មល្លក្សត្រឲ្យបានជ្រាបថា ‹‹ព្រះតថាគត

និងបរិនិព្វានក្នុងទីបំផុតនៃបច្ឆិមយាមក្នុងរាត្រីនេះហើយ កុំឲ្យមល្លក្សត្រទាំងឡាយ មានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយថា ព្រះតថាគតទ្រង់បរិនិព្វានទៅហើយក្នុងស្រុករបស់យើង ។ ទាំងឡាយមិនបានឃើញព្រះតថាគតក្នុងកាលជាទីបំផុតសោះ ។ ព្រះអានន្ទត្ថេរបានទទួលព្រះសុគតអាណត្តិហើយ ក៏កាន់បាត្រនិងចីវរចូលទៅកាន់ក្រុងកុសិនារា ជួនជាវេលានោះ មល្លក្សត្រទាំងឡាយបានចូលមកប្រជុំក្នុងសណ្ឋាគារសាលាដោយករណីយកិច្ចមួយ ព្រះថេរក៏ចូលទៅកាន់ទីប្រជុំនោះថ្លែងដំណឹងថា "អជ្ជ ខោ វាសិដ្ឋ ម្នាលវាសិដ្ឋឧត្តមគោត្រទាំងឡាយ! ការបរិនិព្វាននៃព្រះតថាគតនឹងមានក្នុងទីបំផុត នៃរាត្រីថ្ងៃនេះហើយ, វាសិដ្ឋះទាំងឡាយ! លោកទាំងឡាយចូរប្រញាប់ចេញទៅ (ដើម្បី) កុំឲ្យមានសេចក្តីថ្នាំងថ្នាក់ចិត្តថា "មិនបានចូលគាល់ព្រះតថាគតក្នុងកាលជាទីបំផុត" ដូច្នេះឡើយ ; កាលមល្លក្សត្រព្រមទាំងកូនបុរសនិងកូនសុណិសាប្រជាបតី បានជ្រាបដំណឹងនេះ អំពីសំណាក់ព្រះអានន្ទដ៏មានអាយុហើយ ក៏ទ្រង់ព្រះកន្សែងសោយសោកកានតំនុក ទន្ទឹះខ្សឹកខ្សួលលើកដៃទាំងពីរឡើង ពោលចូរបាច់ដួលទៅលើប្រថពីបរះនេះនៀលហាក់ដូចហត្ថបាទាដាច់ ដោយសេចក្តីស្តាយព្រះ

បរមលោកនាថថា "ព្រះតថាគតជាម្ចាស់ដាច់បរិនិព្វានណាស់ ព្រះសុគតបរិនិព្វានដាច់ណាស់ ដួងចក្ខុក្នុងលោកអន្តរធានទៅដោយដាច់ហើយសណាស់" ។ មល្លក្សត្រទាំងឡាយទ្រង់ស្តេចយាងទាំងទុក្ខសោយសោកទៅដល់សំណាក់ព្រះអានន្ទក្នុងព្រៃសាលវ័ន ។ ព្រះអានន្ទត្ថេរគិតថា "បើឲ្យមល្លក្សត្រចូលទៅក្រាបបង្គំព្រះមានព្រះភាគតាមលំដាប់អង្គ មួយ១.អង្គ ។ គឺនឹងមិនបានថ្វាយបង្គំគ្រប់អង្គ ពត្រីកនឹងភ្លឺស្វាងមុខ, ណ្ហើយចុះយើងនឹងចាត់ដោយបរិវត្តនៃត្រកូលឲ្យចូលក្រាបអភិវាទថ្វាយបង្គំព្រះមានព្រះភាគក្រាបទូលឲ្យជ្រាបថា "មល្លក្សត្រទ្រង់ព្រះនាមនេះ ៗ ព្រមទាំងបុត្រសេនីមហេសី បរិស័ទ អាមាត្យចូលថ្វាយបង្គំព្រះបាទនៃព្រះមានព្រះភាគដោយសិរសានៃខ្លួនៗ ជាលំដាប់ៗដូច្នេះចុះ"; ព្រះអានន្ទត្ថេរ ចាត់ឲ្យមល្លក្សត្រចូលថ្វាយបង្គំព្រះមានព្រះភាគស្រេចហើយ ក្នុងបឋមយាមនៃរាត្រី ។

## ទ្រង់ប្រោសសុភទ្ទបរិព្វាជក

### តេន ខោ បន សមយេន

ក្នុងសម័យនោះមានបរិព្វាជកម្នាក់ឈ្មោះសុភទ្ទអាស្រ័យនៅក្នុងក្រុងកុសិនារា ។ សុភទ្ទបរិព្វាជកនោះបានឮថា "ព្រះសមណគោតមបរម

សាស្តាស្តេចនឹងបរិនិព្វានក្នុងបច្ឆិមយាមនៃរាត្រីថ្ងៃនេះហើយ" ។ សុភទ្ទបរិព្វាជក ក៏នឹកដល់សេចក្ដីដែលខ្លួនបានស្ដាប់ មកអំពីសំណាក់បរិព្វាជកដែលជាអាចារ្យចាស់ៗ ពោលតវាមកថា " កទាចិ ករហចិ តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា អន្តិព្រះតថាគតសម្មាសម្ពុទ្ធទាំងឡាយ តែងឧប្បត្តិឡើងក្នុងលោកមួយដងមួយកាល ការបរិនិព្វាននៃព្រះសមណគោតមនឹងមានក្នុងបច្ឆិមយាម នៃរាត្រីថ្ងៃនេះជាប្រាកដ សេចក្ដីសង្ស័យក្នុងខាងនេះបានកើតឡើងហើយដល់យើង, យើងជាអ្នកមានសេចក្ដីជ្រះថ្លាយ៉ាងនេះថា " ព្រះសមណគោតមបាមសាស្តាអាចសំដែងធម៌ដល់យើង ឲ្យយើងលះសេចក្ដីសង្ស័យនោះចេញបាន គួរប្រញាប់ប្រញាល់ចេញទៅគាល់ព្រះអង្គ ដែលជាមហាសមណឲ្យបានក្នុងរាត្រីថ្ងៃនេះ " ។

លំដាប់នោះ សុភទ្ទបរិព្វាជកបានដើរទៅកាន់សាលវ័ន ចូលទៅដល់សំណាក់ព្រះអានន្ទហើយ ពោលពណ៌នាសេចក្ដីតាមន័យដែលខ្លួនបានត្រិះរិះពុំនោះឲ្យព្រះអានន្ទស្ដាប់ អង្វរសូមចូលគាល់ព្រះមានព្រះភាគ ។ ព្រះអានន្ទទើបហាមឃាត់ថា " អលំ អាវុសោ សុភទ្ទ មាលសុភទ្ទដ៏មានអាយុកុំឡើយ អ្នកកុំបៀតបៀនព្រះតថាគតឲ្យលំបាក,

ព្រះមានព្រះភាគកំពុងលំបាកព្រះកាយណាស់» សុភទ្ទបរិព្វាជកអង្វរករព្រះអានន្ទដល់ពីរបីដង ព្រះអានន្ទក៏នៅតែមិនព្រមបើកឱកាសឲ្យ ។ ព្រះមានព្រះភាគទ្រង់បានឮព្រះអានន្ទចរចាជាមួយនឹងសុភទ្ទបរិព្វាជក ក៏ត្រាស់ហៅព្រះអានន្ទថា "ម្នាលអានន្ទ! កុំ! អានន្ទចូរកុំហាមសុភទ្ទ! ចូរបើកឱកាសឲ្យសុភទ្ទបានឃើញតថាគតចុះ, សុភទ្ទនឹងសួរប្រស្នាណាចំពោះតថាគត ជាអ្នកប៉ុនប៉ងដើម្បីត្រាស់ដឹងទូទៅ ហើយនឹងសួរនូវបញ្ហាទាំងនោះ ដោយមិនមានបំណងសេចក្ដីលំបាកដល់តថាគតឡើយ ម្យ៉ាងទៀត តថាគតដែលសុភទ្ទបានសួរហើយនឹងព្យាករសេចក្ដីណាមួយដល់សុភទ្ទនោះ សុភទ្ទក៏នឹងបានដឹងនូវសេចក្ដីនោះ ដោយឆាប់ហ័ស" ។ លំដាប់នោះ ព្រះអានន្ទត្ថេរទើបហៅសុភទ្ទថា "អាវុសោ សុភទ្ទ ម្នាលសុភទ្ទដ៏មានអាយុ លោកចូរចូលទៅគាល់ចុះ ព្រះមានព្រះភាគទ្រង់បើកឱកាសប្រទានឲ្យលោកចូលទៅគាល់ហើយ ។

សុភទ្ទបរិព្វាជកក៏ចូលទៅគាល់ ធ្វើសម្មោទនីយកថា បដិសណ្ឋារកិច្ច អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរអំពី តិត្ថិយគណាចារ្យទាំង ៦ នាក់គឺ បូរណកស្សបៈ, មក្ខលិគោសាលៈ, អជិតកេសកម្ពលៈ, បកុទ្ធកច្ចាយនៈ, សញ្ជយវេលដ្ឋបុត្តៈ, និគន្ថនាដបុត្តៈ, ដែលត្រូវ

គ្រន៍ពួកគណៈ ជនទាំងឡាយសន្មតហៅថាជាមនុស្សល្អជាមនុស្សប្រ-សើរ (ខ្ញុំព្រះអង្គសូមក្រាបទូលសួរថា តើគ្រូទាំងប្រាំមួយនាក់) "បានត្រាស់ដឹងប្រាជ្ញាដ៏ក្រៃលែងតាមពាក្យប្តេជ្ញារបស់ខ្លួន ៗ គ្រប់ទាំងប្រាំមួយនាក់ឬ ឬមិនត្រាស់ដឹងគ្រប់ទាំងប្រាំមួយនាក់ទេ, ឬក៏ត្រាស់ដឹងចំពោះពួកខ្លះៗប៉ុណ្ណោះ មិនត្រាស់ដឹងដោយក្រៃលែងដោយប្រការដូចម្តេច? „ សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលសុភទ្ទ! អ្នកកុំ (សួររឿងនេះឡើយ) ខនេះចូរលើកទុកទៅចុះ តថាគតនឹងសំដែងធម៌ដល់អ្នកចូរស្តាប់នូវធម៌ ធ្វើទុកក្នុងចិត្តឲ្យសំរេចប្រយោជន៍ចុះ យើងនឹងសំដែងក្នុងកាលឥឡូវនេះ„ ។

កាលសុភទ្ទបរិព្វាជកទទួលពុទ្ធវចនៈដោយគោរពហើយ សម្តេចព្រះមានព្រះភាគទ្រង់ត្រាស់សំដែងធម្មទេសនាថា "ម្នាលសុភទ្ទមគ្គគឺបដិបត្តិមានអង្គ ៨ ប្រការជាអរិយមគ្គប្រាសចាកសត្រូវ ជាមគ្គដ៏ប្រសើរមិនមាននៅក្នុងធម្មវិន័យណាហើយ សមណៈទី ១ ទី ២ ទី ៣ ទី ៤ ក៏មិនមានក្នុងធម្មវិន័យនោះដែរ, ម្នាលសុភទ្ទ មគ្គមានអង្គ ៨ ប្រការជាអរិយមគ្គប្រាសចាកសឹកសត្រូវ ជាមគ្គដ៏ប្រសើរ មាននៅក្នុងធម្មវិន័យណាហើយ សមណបុគ្គលដែលកំចាត់បង់នូវកិលេសនឹងបាបធម៌ក្នុងគិត.

ទី ១ ទី ២ ទី ៣ ទី ៤ រមែងកើតឡើងក្នុងធម្មវិន័យនោះ, ឥមស្មឹ ខោ សុភទ្ទ ធម្មវិនយេ អរិយោ អដ្ឋង្គិកោ មគ្គោ ឧបលព្ភតិ ម្នាលសុភទ្ទ មគ្គមានអង្គ៨ប្រការ ជាអរិយមគ្គ ជាមគ្គដ៏ប្រសើរ មាននៅពិតតែក្នុងធម្មវិន័យនេះ សមណទី ១ ក៏មាននៅតែក្នុងធម្មវិន័យនេះប៉ុណ្ណោះ, សមណទី ២ ទី ៣ ទី ៤ ក៏មាននៅក្នុងតែធម្មវិន័យនេះប៉ុណ្ណោះ អធិប្បាយថា សមណៈ គឺបុគ្គលដែលបានរំងាប់បង់នូវកិលេសនិងបាបធម៌បានដោយពិត ទី ១ គឺ សោតាបន្នបុគ្គល, ទី ២ គឺ សកទាគាមិបុគ្គល, ទី ៣ គឺ អនាគាមិបុគ្គល, ទី ៤ គឺព្រះខីណាស្រព រមែងមានពិតតែក្នុងសម័យធម្មវិន័យនេះប៉ុណ្ណោះ, លទ្ធិសម័យនៃបុគ្គលដទៃក្រៅអំពីព្រះសម្មាសម្ពុទ្ធហើយរមែងសូន្យចាកសមណៈ ព្រោះមិនមានពាក្យប្រៀនប្រដៅដោយប្រការដូចម្ដេចក៏ដោយ ក៏សមណពិសេសទាំងបួនមិនអាចកើតមានឡើងក្នុងលទ្ធិដទៃ ក្រៅអំពីសុគតធម្មវិន័យនេះដែរ, „ ឥមេ ច សុភទ្ទ ភិក្ខូ សម្មាវិហរេយ្យុំ ម្នាលសុភទ្ទ ប្រសិនបើភិក្ខុទាំងឡាយនេះគប្បីនៅដោយល្អនៅដោយប្រពៃហើយ អសុញ្ញោ លោកោ អរហន្តេហិ អស្ស លោកក៏មិនគប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ" ។ សម្ដេចព្រះមានព្រះភាគទ្រង់ត្រាស់ទេសនាធម្មវិន័យ

ជាផ្លូវនិយ្យានិកជាទីកើតនៃសមណៈពិសេស គឺអរិយបុគ្គលទាំង ៤ ពួក ដូច្នេះហើយទ្រង់ត្រាស់ពុទ្ធនិពន្ធតទៅទៀតថា "ម្នាលសុភទ្ទ តថាគត មានអាយុ២៩ឆ្នាំ ដោយវ័យចេញបព្វជ្ជាស្វែងរកថាៈ អ្វីជាកុសលៗ " ដូច្នេះ តាំងពីយើងបានបព្វជ្ជាហើយមកដល់សម័យនេះកំបានចំនួន៥១ ឆ្នាំ ញាណស្ស ធម្មស្ស បទេសវត្តិ ឥតោ ពហិទ្ធា សមណោបិ នត្ថិ សូម្បីពួកសមណៈដែលប្រព្រឹត្តទៅក្នុងប្រទេសនៃធម៌ជាគ្រឿងនាំ ចេញទៅ ក៏មិនមានក្នុងខាងក្រៅអំពីធម្មវិន័យនេះ សមណៈទី ១ ទី ២ ទី ៣ ទី ៤ មិនមានខាងក្រៅអំពីធម្មវិន័យនេះ លទ្ធិសម័យជាគ្រឿង ប្រៀនប្រដៅរបស់អ្នកដទៃសុទ្ធតែសូន្យចាកគុណពិសេសទាំងអស់,ម្នាល សុភទ្ទ បើភិក្ខុទាំងឡាយនេះនៅដោយល្អដោយប្រពៃហើយ លោកក៏ នឹងមិនគប្បីសូន្យចាកព្រះអរហន្តទាំងឡាយឡើយ" ៗ កាលព្រះមាន ព្រះភាគត្រាស់សំដែងធម្មទេសនាដូច្នេះហើយ សុភទ្ទបរិព្វាជកមានសេច ក្តីជ្រះថ្លាក្នុងធម្មទេសនាសំដែងខ្លួនជាឧបាសក ហើយក្រាបទូលសូម បព្វជ្ជាឧបសម្បទាថា " បពិត្រព្រះមានព្រះភាគ ! ខ្ញុំព្រះអង្គគប្បីបាន បព្វជ្ជាឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ" ៗ ព្រះបរមលោក នាថទ្រង់ត្រាស់សំដែង តិត្ថិយបរិវាសវិធីតាមវិនយនិយមថា " ម្នាល

សុភទ្ទ! ជនណាដែលធ្លាប់ចូលជាតិត្ថិយក្នុងកាលមុន កាលបើប្រាថ្នា
បព្វជ្ជាឧបសម្បទាក្នុងធម្មវិន័យនេះ ជននោះត្រូវនៅបរិវាសអស់កាល
កំណត់ ៤ ខែ លុះគន្លង ៤ ខែហើយ ភិក្ខុទាំងឡាយមានចិត្តដែលតិត្ថិយ
ចាស់នោះឲ្យត្រេកអរ ទើបលោកព្រមឲ្យជននោះបានចូលបព្វជ្ជាឧប-
សម្បទាដើម្បីភាវៈជាភិក្ខុ តែជាក្នុងកាលនៅតិត្ថិយបរិវាសនោះ គឺជា-
គតជាអ្នកស្គាល់ប្រមាណក្នុងបុគ្គល គឺលើកលែងដោយពិសេសចំពោះ
បុគ្គលខ្លះដែលមិនគួរនៅបរិវាស ។ សុភទ្ទបរិព្វាជកក្រាបទូលដោយ
សេចក្តីជ្រះថ្លាក្លាហានថា បពិត្រព្រះមានព្រះភាគ បើតិត្ថិយបរិវាស
មានកាលកំណត់ត្រឹមតែ ៤ ខែប៉ុណ្ណោះ ខ្ញុំព្រះអង្គអាចនៅបានយូរដល់
ទៅ ៤ ឆ្នាំ លុះគន្លង៤ឆ្នាំហើយ សូមភិក្ខុទាំងឡាយអនុញ្ញាតឲ្យខ្ញុំ
ព្រះអង្គបានបួសជាភិក្ខុចុះ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទថា "ម្នាល
អានន្ទ! បើដូច្នោះលោកទាំងឡាយចូរបំបួសសុភទ្ទបរិព្វាជកចុះ " ។
ព្រះអានន្ទទទួលពុទ្ធាណត្តិបំបួសសុភទ្ទតាមពុទ្ធបំណង ។ សុភទ្ទ
បរិព្វាជកបានពោលសរសើរព្រះអានន្ទថា " សេចក្តីដែលព្រះសាស្តា
ទ្រង់អភិសេកព្រះអានន្ទដោយអន្តេវាសិកាភិសេកក្នុងកិច្ចដែលព្រះអានន្ទ-

ទទួលចំបួសខ្ញុំព្រះករុណានោះជាលាភយ៉ាងប្រសើររបស់ព្រះអានន្ទ ព្រះអានន្ទបានល្អហើយ» ។ អលត្ថ ខោ សុភទ្ទបរិព្វាជកបានសំរេចបព្វជ្ជាឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។

## សុភទ្ទជាសក្ខិសាវក

អចិរូបសម្បន្នោ ខោ បនាយស្មា សុភទ្ទោ សុភទ្ទភិក្ខុដ៏-មានអាយុលោកឧបសម្បទហើយមិនយូរប៉ុន្មាន បានចេញចាកពួក—គណៈទៅសម្ងំនៅក្នុងទីស្ងាត់តែម្នាក់ឯង ជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងញុំាងកិលេសឲ្យក្តៅសព្វ, មានខ្លួនបញ្ជូនទៅប៉ងចំពោះធម្មាភិសម័យឰដ៏ខាងមុខ, មិនយូរប៉ុន្មានក៏បានសំរេចព្រះអរហត្តផលជាព្រះអរហន្តមួយអង្គ ។ សោ ភគវតោ បច្ឆិមោ សក្ខិសាវកោ អហោសិ លោកជាសក្ខិសាវក គឺសាវកដែលបានឃើញអង្គព្រះសម្មា-សម្ពុទ្ធក្នុងកាលជាទីបំផុត ។ ( ត្រង់ ១ ដែលថាសុភទ្ទភិក្ខុឧបសម្បទហើយបានសំរេចព្រះអរហត្តក្នុងកាលណានោះ ក្នុងបាលីសំដែងតែត្រឹមសេចក្តីថា លោកឧបសម្បទហើយមិនយូរប៉ុន្មាន មិនមានសំដែងដោយត្រង់ថា សំរេចព្រះអរហត្តក្នុងរាត្រីថ្ងៃនោះ តែពាក្យថា ក្នុងសម័យដទៃ កាលដទៃ ត្រោះក្រោយមកក៏មិនបានសំដែងទុកក្នុងបាលីគ្រាន់

តែពោលថាលោកឧបសម្បទហើយមិនយូរប៉ុន្មានប៉ុណ្ណោះ ។ ពាក្យខាង កាយបន្ថែមសេចក្តីថា លោកជាសក្កសាវកអគ្គទីបំផុតរបស់ព្រះមាន-ព្រះភាគ ដូច្នេះគួរសន្និដ្ឋានថា លោកបានសម្រេចព្រះអរហត្តក្នុងក្រៅថ្ងៃនោះ ។ ក្នុងគម្ពីរសុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ ពណ៌នាសេចក្តីក្នុងមហាបរិនិព្វានសូត្រនោះថា “ បានស្តាប់មកថា អានន្ទត្ថេរបាននាំសុភទ្ទបរិព្វាជកទៅក្នុងទីដ៏សមគួរមួយហើយយកទឹកសំកបធាន់ អំពីចំពន់ទឹកមកលាបសិរសាឲ្យជាកហើយ ប្រាប់នូវកម្មដ្ឋានដែលមានស្បែកជាគំរប់៥ (តចបញ្ចកកម្មដ្ឋាន) ជាអារម្មណ៍ហើយ អោរសក់អោរពុកមាត់ ឲ្យស្លៀកសំពត់ដែលជ្រលក់ដោយទឹកអម្ចត់ហើយ ទើបឲ្យក្រែសរណគមន៍សំរេចបព្វជ្ជាជាសាមណេររូបហើយ ទើបនាំមកកាន់សំណាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ឲ្យសុភទ្ទសាមណេរនោះឧបសម្បទហើយទើបប្រាប់នូវកម្មដ្ឋាន ។ សុភទ្ទនោះទទួលយកនូវកម្មដ្ឋាននោះហើយ ក៏អធិដ្ឋានចង្ក្រមក្នុងសាលវននៃឧទ្យាននោះ លោកបន្តសេចក្តីព្យាយាមមិនឈប់ ញាំងវិបស្សនាបញ្ញាឲ្យបរិសុទ្ធមិនចកប្រាសចាកឧបក្កិលេស ក៏បានសំរេចអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយហើយចូលទៅថ្វាយបង្គំព្រះមានព្រះភាគអង្គុយក្នុងទីដ៏សមគួរ ។

ព្រះធម្មសង្គាហកត្ថេរ អាស្រ័យសេចក្ដីដែលបានពោលមកហើយនេះ ទើបពោលថា "លោកនុចសម្បុទហើយមិនយូរ" ។ល។ ដូច្នេះ ក្នុងបាលីមហាបរិនិព្វានសូត្រនោះព្រះអដ្ឋកថាចារ្យ លោកពណ៌នាអំពីបច្ឆិមឧបសម្បទានៃព្រះសុភទ្ទដ៏មានអាយុនោះដោយប្រការដូច្នេះ ។

## ប្រទានឱវាទដល់ភិក្ខុសង្ឃ

អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទឲ្យជាអ្នកទទួលទេសនាប្រទានពុទ្ធោវាទដល់ភិក្ខុបរិស័ទ ដើម្បីឲ្យមានសេចក្ដីគោរពចំពោះព្រះធម៌និងព្រះវិន័យដ៏កល់ទុក ( នូវព្រះធម៌និងព្រះវិន័យនោះ ) ក្នុងឋានៈជាព្រះសាស្ដាថា សិយា ខោ បនានន្ទ តុម្ហាកំ ឯវមស្ស អតីតសត្ថុកំ បាវចនំ នត្ថិ នោ សត្ថាតិ ម្នាលអានន្ទ! សេចក្ដីត្រិះរិះថា "បាវចនគឺសាសនធម៌ដែលមានព្រះសាស្ដាកន្លងហើយ, ព្រះសាស្ដានៃយើងទាំងឡាយមិនមាន" ដូច្នេះ, យ៉ាងនេះនឹងគប្បីមានដល់អ្នកទាំងឡាយ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ ម្នាលអានន្ទ! លោកទាំងឡាយមិនគប្បីយល់ឃើញយ៉ាងនេះឡើយ" យោ វោ អានន្ទ មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ សោ វោ មមច្ចយេន សត្ថា ។

ម្នាលអានន្ទ! ធម៌និងវិន័យណា ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយ ដល់អ្នកទាំងឡាយ ធម៌និងវិន័យនោះ នឹងជាសាស្តានៃអ្នកទាំងឡាយក្នុងកាលអំណឹះអំពីតថាគតទៅ ។

ទ្រង់ត្រាស់អនុញ្ញាតឲ្យភិក្ខុហៅគ្នាដោយគារវោហារ

យថា ខោ បនានន្ទ ឯតរហិ ភិក្ខូ អញ្ញមញ្ញំ អាវុសោ វាទេន សមុទាចរន្តិ ន ខោ មមច្ចយេន ឯវំ សមុទាចរិតព្វំ (ថេរតរេន អានន្ទ ។ល។ សមុទាចរិតព្វោ សម្តេចព្រះមានព្រះភាគទ្រង់ប្រាប់ភិក្ខុបរិស័ទឲ្យសំគាល់នូវធម៌និងវិន័យជាសាស្តា ដោយប្រការដូច្នេះហើយ ទើបទ្រង់សំដែងនូវបរិតបរណ៌ក្នុងអនាគត ដើម្បីឲ្យភិក្ខុហៅគ្នានឹងគ្នាដោយវោហារដ៏សមគួរដល់ភិក្ខុដែលមានវស្សាច្រើននិងតិច ទើបទ្រង់ត្រាស់ដល់ព្រះអានន្ទថា „ម្នាលអានន្ទ! ឥឡូវនេះ ភិក្ខុទាំងឡាយតែងហៅគ្នាដោយពាក្យថា "អាវុសោ" ទាំងចាស់ទាំងខ្ចីលុះកន្លងអំពីតថាគតទៅលោកទាំងឡាយកុំគប្បីហៅគ្នាដូច្នេះទៀតឡើយ, ភិក្ខុជាថេរៈ (ចាស់វស្សា) គប្បីហៅភិក្ខុដែលមានវស្សាខ្ចីជាងខ្លួនដោយឈ្មោះដោយគោត្រ (ឬដោយពាក្យថា អាវុសោក៏បាន) ចំណែកភិក្ខុថ្មីវស្សាខ្ចីជាង គប្បីហៅភិក្ខុជាថេរៈដែលមានវស្សាចាស់ជាងខ្លួនថា "ភន្តេ" ឬ "អាយស្មា"

កាមសមត្ថដែលជាគាររាំហារ" ។

## វិធីដាក់ព្រហ្មទណ្ឌ

អាកង្ខមានោ អានន្ទ សង្ឃោ មមច្ចយេន ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ សមូហនតុ ម្នាលអានន្ទ កាលបើសង្ឃប្រាថ្នានឹងដកសិក្ខាបទតូចតាចចេញខ្លះ លុះអំណឹះពីតថាគតទៅក៏គួរដកចុះ

ឆន្នស្ស អានន្ទ ភិក្ខុនោ មមច្ចយេន ព្រហ្មទណ្ឌោ កាតព្វោ ម្នាលអានន្ទ លុះអំណឹះពីតថាគតទៅហើយ សង្ឃគប្បីធ្វើព្រហ្មទណ្ឌដល់ឆន្នភិក្ខុចុះ ។

អានន្ទក្រាបទូលសួរថា កតមោ បន ភន្តេ ព្រហ្មទណ្ឌោ បពិត្រព្រះអង្គដ៏ចំរើន ព្រហ្មទណ្ឌនោះតើដូចម្ដេច? ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ឆន្នោ អានន្ទ ភិក្ខុ យំ ឥច្ឆេយ្យ តំ វទេយ្យ ម្នាលអានន្ទ ឆន្នភិក្ខុ គប្បីប្រាថ្នាថាពោលនូវពាក្យណា ក៏គប្បីពោលនូវពាក្យនោះចុះ ឆន្នភិក្ខុនោះគឺភិក្ខុទាំងឡាយមិនគប្បីស្ដីថាមិនគប្បីទូន្មានមិនគប្បីប្រៀនប្រដៅឡើយ ។ នេះឈ្មោះថាព្រហ្មទណ្ឌ ។

អថ ខោ ភគវា ភិក្ខូ អាមន្តេសិ លំដាប់នោះព្រះមានព្រះភាគទ្រង់ឲ្យហៅភិក្ខុទាំងឡាយមកថា សិយា ខោ បន ភិក្ខវេ ឯក

ភិក្ខុស្សាបិ កង្ខា វា វិមតិ វា ពុទ្ធេ វា ធម្មេ វា សង្ឃេ វា មគ្គេ វា បដិបទាយ វា ម្នាលអានន្ទ ភិក្ខុទាំងឡាយ បើសេចក្តីឆ្ងល់ ឬសេចក្តីសង្ស័យ ក្នុងព្រះពុទ្ធក្តី ក្នុងព្រះធម៌ក្តី ក្នុងព្រះសង្ឃក្តី ក្នុងមគ្គក្តី ក្នុងបដិបទាក្តី នឹងគប្បីមានខ្លះដល់ភិក្ខុណាមួយ លោកទាំងឡាយចូរសាកសួរចុះ លោកទាំងឡាយចូរកុំមានវិប្បដិសារីសេចក្តីក្តៅក្រហាយខាងក្រោយថា "កាលព្រះសាស្តាទ្រង់គង់នៅក្នុងទីចំពោះមុខ យើងទាំងឡាយមិនអាចដើម្បីនឹងទូលសួរក្នុងទីចំពោះព្រះភក្ត្រ" ។

កាលព្រះមានព្រះភាគទ្រង់ត្រាស់អនុញ្ញាតបើកឱកាសឲ្យទូលសួរដូច្នោះហើយ ភិក្ខុទាំងឡាយក៏នៅស្ងៀម លុះព្រះអង្គទ្រង់ត្រាស់ដូច្នោះអស់វារៈ ៣ដង ភិក្ខុទាំងឡាយក៏នៅស្ងៀមគ្រប់អង្គ ក្នុងពុទ្ធបរិវារមណ្ឌលនោះព្រះអានន្ទក្រាបទូលថា "បពិត្រព្រះមានព្រះភាគ! ខនេះគួរអស្ចារ្យណាស់ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាណាស់ចំពោះភិក្ខុទាំងឡាយ ដែលមិនមានសេចក្តីសង្ស័យក្នុងព្រះរតនត្រ័យ ក្នុងមគ្គ ក្នុងបដិបទា សូម្បីតែមួយអង្គក៏គ្មាននៅក្នុងភិក្ខុសង្ឃពួកនេះដែរ" ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលអានន្ទ! ដែលលោកពោលនេះព្រោះសេចក្តីជ្រះថ្លាពិតមែនហើយ ញាណនៃតថាគតក៏អាចជ្រួតជ្រាបក្នុងការណ៍នេះដែរ, តាមសេចក្តីពិតថា

សេចក្តីសង្ស័យក្នុងព្រះពុទ្ធព្រះធម៌ព្រះសង្ឃក្នុងមគ្គឬក្នុងបដិបទាមិនមាន ដល់ភិក្ខុសូម្បីមួយរូបក្នុងពួកភិក្ខុសង្ឃនេះ, ព្រោះថាភិក្ខុទាំង ៥០០ រូប នេះ យ៉ាងថយណាស់ក៏បានសំរេចគុណពិសេសត្រឹមថ្នាក់សោតា មានកាយមិនសាបសូន្យជាធម្មតា, និយមបានប្រាកដជា ពិតជាត្រាស់ដឹងគុណពិសេសថ្នាក់ខ្ពស់ក្នុងអនាគតមិនខាន ភិក្ខុទាំង ៥០០ នេះសុទ្ធតែអរិយបុគ្គល មិនលាយឡំដោយបុថុជ្ជនឡើយ ។

## បច្ឆិមោវាទ

អថ ខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្ត-យាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។

លំដាប់នោះព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកប្រ-ទានបច្ឆិមោវាទថា “ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតតឿនអ្នកទាំងឡាយឲ្យដឹងថាសង្ខារធម៌ មានសេចក្តីវិនាសសាបសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួង ដែលជាប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃឲ្យបានបរិបូណ៌ដោយសេចក្តីមិនប្រមាទចុះ ” ។ អយំ តថាគតស្ស បច្ឆិមា វាចា នេះជាវាចាទីបំផុតរបស់ព្រះតថាគត ។

គ្រានោះ ព្រះមានព្រះភាគស្តេចទ្រង់សម្រេចសីហសេយ្យាលើ

សេយ្យាសនៈជាទីបរិនិព្វាន ព្រះអង្គបានប្រមូលនូវព្រះឱវាទទាំងពួង ដែលទ្រង់បានប្រទានមកអស់ ៤៥ ព្រះវស្សានោះ មកប្រជុំចុះក្នុងសេចក្តីមិនប្រមាទ ប្រទានដល់ភិក្ខុសង្ឃពុទ្ធបរិស័ទ ក្នុងអវសានកាលដោយប្រការដូច្នេះ ។

## បរិនិព្វាន

តមកព្រះអង្គមិនបានសំដែងពុទ្ធវចនណាទៀតឡើយ ទ្រង់ធ្វើបរិនិព្វានបរិកម្មដោយអនុបុព្វវិហារសមាបត្តិ ៩, ព្រះធម្មសង្គាហកត្ថេរទាំងឡាយបានសំដែងទុកដូចតទៅនេះ

អថ ខោ ភគវា បឋមជ្ឈានំ សមាបជ្ជិ: បឋមជ្ឈានា វុដ្ឋហិត្វា ទុតិយជ្ឈានំ សមាបជ្ជិ ទុតិយជ្ឈានា វុដ្ឋហិត្វា តតិយជ្ឈានំ សមាបជ្ជិ តតិយជ្ឈានា វុដ្ឋហិត្វា ចតុត្ថជ្ឈានំ សមាបជ្ជិ ចតុត្ថជ្ឈានា វុដ្ឋហិត្វា អាកាសានញ្ចាយតនំ សមាបជ្ជិ អាកាសានញ្ចាយតនសមាបត្តិយា វុដ្ឋហិត្វា វិញ្ញាណញ្ចាយតនំ សមាបជ្ជិ វិញ្ញាណញ្ចាយតនសមាបត្តិយា វុដ្ឋហិត្វា អាកិញ្ចញ្ញាយតនំ សមាបជ្ជិ អាកិញ្ចញ្ញាយតនសមាបត្តិយា វុដ្ឋហិត្វា នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា វុដ្ឋហិត្វា សញ្ញាវេទយិតនិរោធំ សមាបជ្ជិ ។

អថ ខោ អាយស្មា អានន្ទោ អាយស្មន្តំ អនុរុទ្ធំ ឯតទវោច
បរិនិព្វុតោ ភន្តេ អនុរុទ្ធ ភគវាតិ ។ នាវុសោ អានន្ទ ភគវា
បរិនិព្វុតោ សញ្ញាវេទយិតនិរោធំ សមាបន្នោតិ ។ អថ ខោ ភគវា
សញ្ញាវេទយិតនិរោធសមាបត្តិយា វុដ្ឋហិត្វា នេវសញ្ញានាសញ្ញាយតនំ
សមាបជ្ជិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា វុដ្ឋហិត្វា អាកិញ្ច-
ញ្ញាយតនំ សមាបជ្ជិ អាកិញ្ចញ្ញាយតនសមាបត្តិយា វុដ្ឋហិត្វា
វិញ្ញាណញ្ចាយតនំ សមាបជ្ជិ វិញ្ញាណញ្ចាយតនសមាបត្តិយា វុដ្ឋ-
ហិត្វា អាកាសានញ្ចាយតនំ សមាបជ្ជិ អាកាសានញ្ចាយតនសមា-
បត្តិយា វុដ្ឋហិត្វា ចតុត្ថំ ឈានំ សមាបជ្ជិ ចតុត្ថា ឈានា
វុដ្ឋហិត្វា តតិយំ ឈានំ សមាបជ្ជិ តតិយា ឈានា វុដ្ឋហិត្វា
ទុតិយំ ឈានំ សមាបជ្ជិ ទុតិយា ឈានា វុដ្ឋហិត្វា បឋមំ
ឈានំ សមាបជ្ជិ បឋមា ឈានា វុដ្ឋហិត្វា ទុតិយំ ឈានំ
សមាបជ្ជិ ទុតិយា ឈានា វុដ្ឋហិត្វា តតិយំ ឈានំ សមាបជ្ជិ
តតិយា ឈានា វុដ្ឋហិត្វា ចតុត្ថំ ឈានំ សមាបជ្ជិ ចតុត្ថា
ឈានា វុដ្ឋហិត្វា សមនន្តរា ភគវា បរិនិព្វាយិ ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចូលកាន់បឋមជ្ឈានចេញចាក

បឋមជ្ឈានហើយ ចូលកាន់ទុតិយជ្ឈានចេញចាកទុតិយជ្ឈានហើយ ចូលកាន់តតិយជ្ឈានចេញចាកតតិយជ្ឈានហើយ ចូលកាន់ចតុត្ថជ្ឈានចេញចាកចតុត្ថជ្ឈានហើយ ចូលកាន់អាកាសានញ្ចាយតនៈ ចេញចាកអាកាសានញ្ចាយតនសមាបត្តិហើយ ចូលកាន់វិញ្ញាណញ្ចាយតនៈចេញចាកវិញ្ញាណញ្ចាយតនសមាបត្តិហើយ ចូលកាន់អាកិញ្ចញ្ញាយតនៈចេញចាកអាកិញ្ចញ្ញាយតនសមាបត្តិហើយ ចូលកាន់នេវសញ្ញានាសញ្ញាយតនៈចេញចាកនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ចូលកាន់សញ្ញាវេទយិតនិរោធសមាបត្តិ រំលត់ចិត្តសង្ខារ គឺសញ្ញានឹងវេទនា ។ (ព្រះអង្គទ្រង់ចូលអនុបុព្វវិហារសមាបត្តិទាំង៩ ដោយប្រការដូច្នេះ) ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានសួរព្រះអនុរុទ្ធត្ថេរថា "បពិត្រព្រះអនុរុទ្ធ ដ៏មានអាយុ ! ព្រះមានព្រះភាគទ្រង់បរិនិព្វានហើយឬ?" "ម្នាលអានន្ទ! ព្រះមានព្រះភាគមិនទាន់បរិនិព្វាននៅឡើយទេ ស្តេចចូលដល់សញ្ញាវេទយិតនិរោធសមាបត្តិ" ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់នៅក្នុងនិរោធសមាបត្តិ តាមសមគួរដល់កាលដែលព្រះអង្គកំណត់ហើយ ស្តេចចេញចាកនិរោធសមាបត្តិ ចូលកាន់នេវសញ្ញានាសញ្ញាយតនៈ ទ្រង់ចេញចាកនេវសញ្ញា

នាសញ្ញាយតនៈ ចូលកាន់អាកិញ្ចញ្ញាយតនៈ ទ្រង់ចេញចាកអាកិញ្ចញ្ញាយតនៈហើយ ចូលកាន់វិញ្ញាណញ្ចាយតនៈ ទ្រង់ចេញចាកវិញ្ញាណញ្ចាយតនៈហើយ ចូលកាន់អាកាសានញ្ចាយតនៈ ទ្រង់ចេញចាកអាកាសានញ្ចាយតនៈ ចូលកាន់ចតុត្ថជ្ឈាន ទ្រង់ចេញចាកចតុត្ថជ្ឈានហើយ ចូលកាន់តតិយជ្ឈានទ្រង់ចេញចាកតតិយជ្ឈានហើយ ចូលកាន់ទុតិយជ្ឈានទ្រង់ចេញចាកទុតិយជ្ឈានហើយ· ចូលកាន់បឋមជ្ឈាន ទ្រង់ចេញចាកបឋមជ្ឈានហើយ ចូលកាន់ទុតិយជ្ឈាន ទ្រង់ចេញចាកទុតិយជ្ឈានហើយ ចូលកាន់តតិយជ្ឈានទ្រង់ចេញចាកតតិយជ្ឈានហើយ ចូលកាន់ចតុត្ថជ្ឈាន ទ្រង់ចេញចាកចតុត្ថជ្ឈាន ព្រះមានព្រះភាគក៏ទ្រង់បរិនិព្វាន ក្នុងលំដាប់នៃការពិចារណានូវអង្គនៃចតុត្ថជ្ឈាន (ក្នុងបច្ចិមយាមនៃរាត្រីវិសាខបុណ្ណមី មហាមង្គលសម័យ ដោយប្រការដូច្នេះ ។

កាលសម័យព្រមគ្នានឹងបរិនិព្វានកាលនៃព្រះមានព្រះភាគនោះ សហម្បតីព្រហ្មបានពោលគាថាសំដែងសេចក្តីសង្វេគ នឹងសេចក្តីជ្រះថ្លារបស់ខ្លួនថា

សព្វេ វ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ
យត្ថ ឯតាទិសោ សត្ថា លោកេ អប្បដិបុគ្គលោ

តថាគតោ ពលប្បត្តោ សម្ពុទ្ធោ បរិនិព្វុតោ

សេចក្តីថា បណ្តាសត្វសត្វឥតមានសល់ក្នុងលោក សុទ្ធតែត្រូវចោលរាងកាយគេទុកលើផែនពសុធា, ក្នុងលោកណាហ្ន៎ (ដែលសត្វមិនត្រូវចោលរាងកាយនៅលើផែនដី) សូម្បីតែអង្គព្រះតថាគតសម្ពុទ្ធបរមគ្រូជាសាស្តាឯក ទ្រង់នូវគុណដ៏ធំលើសលុប ឥតមាននរណាប្រៀបបានជាសយម្ភូញាណត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ទ្រង់ដល់នូវពលញាណមានកម្លាំង ១០ ប្រការនៅតែមិនគង់នៅជាស្ថាពរ ទ្រង់ចូលបរិនិព្វានទៅហើយ គួរឲ្យសង្វេគតក់ស្លុតណាស់ ។

## សក្កទេវរាជបានពោលថា

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សេចក្តីថា សង្ខារដែលបច្ច័យទាំងឡាយប្រជុំតាក់តែងមកមិនទៀងមិនពិត មានការកើតឡើងហើយតែងសូន្យទៅវិញជាធម្មតា រមែងកើតឡើងហើយតែងរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយទើបបាននូវសេចក្តីសុខត្រជាក់ ។

## ព្រះអនុរុទ្ធត្ថេរលោកបានពោលថា

នាហុ អស្សាសបស្សាសោ ឋិតចិត្តស្ស តាទិនោ
អនេញ្ជោ សន្តិមារព្ភ យំ កាលមកាសិ មុនិ
អសល្លីនេន ចិត្តេន វេទនំ អជ្ឈវាសយិ
បជ្ជោតស្សេវ និព្វានំ វិមោក្ខោ ចេតសោ អហុ ។

សេចក្តីថា ព្រះសម្ពុទ្ធបរមគ្រូទ្រង់មានព្រះទ័យឋិតនៅមិនញាប់ញ័រ ដោយលោកធម៌ទាំង ៨ ប្រការ ព្រះអង្គមានខ្យល់អស្សាសបស្សាស លែងហើយ ព្រះមុនីលោកនាថមិនមានព្រះទ័យតក់ស្លុតចំពោះមរណៈ-ធម៌ឡើយ ទ្រង់ប្រារព្ធនូវសន្តិ គឺសេចក្តីស្ងប់មានព្រះនិព្វានជាអារម្មណ៍ ធ្វើនូវកាលៈដែលផុតវិស័យនៃសាមញ្ញជន មានព្រះទ័យសឹងអត់សង្កត់ចំពោះទុក្ខវេទនាដោយសតិនឹងសម្បជញ្ញៈ ដ៏ឧត្តមផុតរលត់ ដោយអនុបាទិសេសនិព្វាន មានឧបមាដូចជាប្រទីប ដ៏រុងរឿងដែលរលត់ស្ងប់ខ្យល់ទៅដូច្នោះ ។

## ព្រះអានន្ទពោលថា

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
សព្វាការវរូបេតេ សម្ពុទ្ធេ បរិនិព្វុតេ

សេចក្ដីថា កាលព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ប្រកបដោយអាការៈដ៏ប្រសើរទាំងពួង រំលត់ខន្ធចូលកាន់ព្រះនិព្វានហើយ សេចក្ដីអស្ចារ្យគួរឲ្យភ្ញាក់ភ្លឹកព្រឺរោមព្រឺស្បែកគួរស្ញប់ស្ញែង បានកើតមានឡើងប្រាកដដល់ទេវតានឹងមនុស្សទាំងឡាយ ។

លោកទាំង ៤ រូបបានពោលគាថាសំវេជនីយ៍សេចក្ដីសង្វេគនៃខ្លួន ៗ ដោយប្រការដូច្នេះ ។

គាថាសំវេជនីយ៍ពីការបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធដូចសំដែងមកហើយនេះ គួរជាទីតាំងនៃសេចក្ដីសង្វេគដល់បណ្ឌិតជនទាំងឡាយណាស់ សាធុជនជាបណ្ឌិតទាំងឡាយ កាលបើបានស្ដាប់ហើយ បានដឹងនូវការប្រព្រឹត្តទៅរបស់សង្ខារដោយអនិច្ចតាទិធម៌ រមែងសាបសូន្យទៅជាធម្មតា មិនគួរប្រហែសធ្វេសឡើយ ព្រោះរាងកាយដែលមាន វេទនា សញ្ញា ចេតនា គ្រប់គ្រងនេះ រមែងធ្លាក់ចុះក្នុងវិស័យនៃជរានឹងមរណៈ ឥតមានបុគ្គលណាមួយរួចផុតបានឡើយ សូម្បីតែអង្គព្រះសម្ពុទ្ធបរមគ្រូ ដែលជាសាស្ដាឯកក្នុងលោកឥតមានបុគ្គលណាប្រៀបស្មើបាន គង់ស្ដេចរំលត់ខន្ធចូលកាន់ព្រះនិព្វានចៀសវាងពុំរួច គួរសាធុជនគប្បីមានសេចក្ដីសង្វេគហើយមិនប្រមាទ ស្វែងរក

នូវឧបាយជាទីពឹងសំរាប់ខ្លួន ក្នុងកុសលធម្មានុយោគបដិបត្តិ ដើម្បីឲ្យឆាប់បានសំរេចព្រះនិព្វាន អស់កាលជានិច្ចនិរន្តរ៍កុំបីខានឡើយ ។

ប្រវត្តិនៃព្រះសម្ពុទ្ធដែលពណ៌នាមកនេះ ជាគ្រឿងសំដែងនូវគុណបានដល់សម្បត្តិទាំង ៣ គឺហេតុសម្បត្តិ ១; ផលសម្បត្តិ ១ សត្តូប-ការសម្បត្តិ ១ ។

" ហេតុ " នោះគឺមហាករុណាសមាយោគ ដែលបានក្រាលគ្របដណ្ដប់លើពពួកសត្វដ៏ច្រើនលើសលុប តាំងនៅក្នុងសន្តានមិនមានសាយជាហេតុខាងដើមប្រការ ១ សេចក្ដីខ្វល់ខ្វាយសាងសន្សំព្រះពោធិសម្ភារ បំពេញពុទ្ធការកធម៌ តាមថ្នាក់តាំងពីជាន់ទាបឡើងដល់ជាន់ឧក្រិដ្ឋឥតមានធរណៈមួយស្មើបាន អស់កាលយូរអង្វែងកប្បកល្បជាហេតុប្រការ ១ កិច្ចទាំងពីរនេះជាចំណែកខាងដើម ដែលនាំឲ្យសម្រេចផលនឹងសត្តូបការៈទើបឈ្មោះថាហេតុ ។ ផលគឺ ញាណសម្បត្តិ១ បហានសម្បត្តិ១ អានុភាវសម្បត្តិ១ រូបកាយសម្បត្តិ១ ។ ព្រះប្រាជ្ញាញាណដែលដឹងច្បាស់ក្នុងមគ្គទាំងបួន ជាទីតាំងនៃសព្វញ្ញុតញ្ញាណ ព្រមទាំងញាណដទៃទៀតមានទសពលញ្ញាណជាដើម ព្រះញាណទាំងពួងនេះឈ្មោះថាញាណសម្បត្តិ ។ ការដែលព្រះអង្គញុំាងកិលេសឲ្យ

ស្ងួតស្ងប់ស្ងៀមអស់ទៅ  មានការកើតឡើងក្នុងសន្ដានមិនបានទៀតជាធម្មតា ឈ្មោះថាបហានសម្បទា ។ ការដែលព្រះអង្គទ្រង់ជាអធិបតីស្ទាត់ជំនាញក្នុងការសំដែងឫទ្ធិជាឥស្សរៈ ក្នុងព្រះហឫទ័យអាចឲ្យប្រព្រឹត្តទៅបានតាមពុទ្ធបំណងគ្រប់ប្រការឈ្មោះថា អានុភាវសម្បទា ។ ការបរិបូណ៌ដោយអត្តភាពដែលប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ប្រការនឹងអនុព្យញ្ជនៈ៨០ដែលជានយនាភិសេករបស់សកលលោក ឈ្មោះថា រូបកាយសម្បទា ។ គុណទាំង ៤ ប្រការនេះមានបរិបូណ៌ឡើងបាន ក៏ព្រោះអាស្រ័យហេតុ ២ ប្រការខាងដើមនោះ ទើបឈ្មោះថាផល ។ សត្តូបការៈ ការសង្គ្រោះស្រោចស្រង់ពួកសត្វមាន ២ យ៉ាងគឺ អាសយៈ១, បយោគ ១ ។ ការដែលព្រះអង្គមានព្រះហឫទ័យត្រជាក់ត្រជុំដោយមហា-ករុណាធិគុណ ប្រាថ្នាប្រយោជន៍ដល់សត្វជានិច្ច សូម្បីក្នុងសត្វដែលមាននិស្ស័យខុសគ្រោតគ្រាតដូចជាទេវទត្តជាដើមក៏ដោយ ឈ្មោះថាអាសយសម្បទា ។ ការដែលព្រះអង្គមិនមានពុទ្ធបំណងចំពោះអាមិសហើយសំដែងធម្មទេសនាប្រៀនប្រដៅវេនេយ្យសត្វ ដោយយានត្រ័យគឺ សីល , សមាធិ, បញ្ញា ដែលជាបដិបទាទៅកាន់ព្រះនិព្វាន ញ៉ាំងសត្វដែលមានឧបនិស្ស័យឲ្យបានត្រាស់ដឹងក្នុងលោកុត្តរធម៌ ជាអរិយសម្បត្តិ

ឈ្មោះជាបយោគសម្បទា ។ សត្តូបការសម្បទាទាំងពីរនេះ មានបរិបូណ៌គ្រប់គ្រាន់ក្នុងសន្តាននៃព្រះតថាគត ។ សូមសាធុជនទាំងឡាយទ្រទ្រង់ចាំទុកនូវសម្បទាគុណទាំង ៣ នេះដោយល្អ ហើយចូររលឹកដល់គុណព្រះពុទ្ធនេះជានិច្ច កល់ចិត្តកត្រៀវទៅ ។

## អបរកាល

## ថ្វាយព្រះភ្លើងព្រះពុទ្ធសរីរៈ

កាលព្រះបរមគ្រូសម្មាសម្ពុទ្ធទ្រង់រំលត់ខន្ធចូលបរិនិព្វានហើយ កត្រៃនោះពុំទាន់ភ្លឺស្រឡះច្បាស់នៅឡើយ ព្រះអនុរុទ្ធនិងព្រះអានន្ទគិសំដែងធម្មកថា ឲ្យបរិស័ទមានសេចក្តីសង្វេគហើយជ្រះថ្លាតាមសមគួរដល់កាលនិងតាមសមគួរដល់បរិស័ទ ។ លុះភ្លឺស្រឡះហើយព្រះអនុរុទ្ធត្ថេរបានបញ្ជាឲ្យព្រះអានន្ទទៅប្រាប់មល្លក្សត្រ នៅក្រុងកុសិនារាឲ្យបានជ្រាបដំណឹងអំពីបរិនិព្វាននៃព្រះតថាគត ។ គ្រានោះមល្លក្សត្រក៏ពុងប្រជុំព្រមគ្នានៅសណ្ឋាគារស្ថាន ដោយករណីយកិច្ចជាប់ដោយពុទ្ធបរិនិព្វាននោះឯង ទ្រង់ធ្វើទុកក្នុងចិត្តចាំប្រតិបត្តិតាមពុទ្ធដំណាន់ដឹងរបកពិព្យាយថាទីងមកក្នុងកត្រៃនោះ លុះព្រះអានន្ទត្ថេរនិមន្តទៅដល់ចូលទៅក្នុងសណ្ឋាគារសោលាសំដែងដំណឹងឲ្យមល្លក្សត្រជ្រាបថា "ព្រះមានព្រះភាគទ្រង់

បរិនិព្វានហើយ ។ មល្លក្សត្រទាំងឡាយបានប្រារព្ធដំណើរនោះហើយ ក៏ទ្រង់រៀបយកគ្រឿងក្រឡូលជ្រលក្នុងទូក ដោយយកកម្លាំងសេចក្ដីជ្រះថ្លាចំពោះព្រះមានព្រះភាគ ដោយមានបំណងថា បន់ឲ្យព្រះអង្គគង់នៅមាននៅអស់កាលដ៏យូរ ព្រះអង្គជាជួនចក្ខុមិនគួរមកអន្តរធានចាកលោកឆាប់ពេកដូច្នេះសោះ ។ គ្រានោះ មល្លក្សត្រក៏បញ្ជាការឲ្យបុរសទាំងឡាយដើរប្រកាសឃោសនាសព្វទីស្ថានក្នុងនគរកុសិនារា ប្រាប់ឲ្យនាំបណ្ដាសុគន្ធជាតិគ្រឿងក្រអូបផ្កាកម្រង និងតូរ្យតន្ត្រីទាំងប៉ុន្មានមកប្រជុំគ្នាហើយ ពួកមល្លក្សត្រក៏នាំនូវសុគន្ធជាតិផ្កាកម្រងនិងតូរ្យតន្ត្រីទាំងនោះ ព្រមទាំងសំពត់ ៥០០ ផ្ទាំងទៅកាន់ព្រៃសាលវ័នធ្វើនូវសក្ការបូជាព្រះសរីរៈព្រះមានព្រះភាគ ដោយចម្រៀងប្រគំតូរ្យតន្ត្រីនិងគ្រឿងក្រអូបដ៏ច្រើនឡើងកែជាអនេកប្បការ រៀបចំតាក់តែងទីកន្លែងធ្វើជាកន្លមូលដ៏មានពិតានប្រដាប់ដោយបុប្ផជាតិ ដំកល់ទុកជាបរិវារនៃព្រះសរីរៈ ។ លុះទិវាកត្រៃថ្ងៃយប់កន្លងទៅ ពួកមល្លក្សត្រទាំងនោះបានសម្រេចមតិថា ថ្ងៃនេះព្រលប់ហួសហើយ ចាំវេលាស្អែកនេះចុះយើងនឹងនាំថ្វាយព្រះភ្លើងបូជាព្រះពុទ្ធសរីរៈ នៃព្រះមានព្រះភាគ ។ ពេលនោះ មល្លក្សត្រទាំងឡាយបានធ្វើពុទ្ធបូជាព្រះពុទ្ធសរីរៈដ៏មហោ

ព្យួរដោយន័យនេះអស់ការៈ ៦ ថ្ងៃមកហើយ លុះដល់ថ្ងៃ ទី ៧ មល្លក្សត្រទាំងឡាយច្រឹកក្រគ្នាថា យើងនឹងនិមន្តព្រះពុទ្ធសរីរៈប្រទក្សិណព្រះនគរថ្វាយព្រះភ្លើងព្រះពុទ្ធសរីរៈក្នុងទិសទក្សិណ ខាងក្រៅព្រះនគរចុះ ។ គ្រានោះមល្លបាមោក្ខ ៨ អង្គ ប្រុងប្រង់នូវកម្លាំងច្រើនស្រោចស្រង់កាយឲ្យបរិសុទ្ធស្អាតហើយ ប្រដាប់កាយដោយសំពត់ថ្មីព្រមគ្នាចូលទៅនិមន្តព្រះសរីរៈ តែមិនអាចញុំាងព្រះសរីរៈឲ្យកម្រើកចាកទីបាន មល្លក្សត្រទាំងឡាយមានសេចក្តីចំឡែកអស្ចារ្យក្នុងចិត្ត ទើបចូលទៅទូលសួរព្រះអនុរុទ្ធត្ថេរ លោកសំដែងហេតុប្រាប់ថា ទេវតាទាំងឡាយគិតថានឹងនិមន្តព្រះពុទ្ធសរីរៈទៅខាងឧត្តរទិសនៃនគរ ចូលកាន់ព្រះនគរវិញតាមឧត្តរទ្វារនិមន្តទៅចំពាក់កណ្តាលនៃព្រះនគរ ចេញទៅតាមទ្វារទិសខាងកើតហើយនិមន្តទៅប្រតិស្ឋានថ្វាយព្រះភ្លើងនា មកុដពន្ធនចេតិយក្រង់ទិសខាងកើតនៃពជជាទីកុសិនារា ទេវតាទាំងឡាយមានមតិយ៉ាងនេះ ចំណែកមតិរបស់មល្លក្សត្រទាំងឡាយផ្សេងពីនេះ បានជាមិនអាចនិមន្តព្រះសរីរៈឲ្យឃ្លាតចាកទីបាន ។ មល្លក្សត្រទាំងឡាយក៏យល់ព្រមស្របតាមបំណងរបស់ទេវតាទាំងឡាយ តមកក៏ប្រុងប្រៀបនឹងនិមន្តព្រះសរីរៈទៅដោយឧត្តរទ្វារមិនឲ្យខុសពីទេវាធិប្បាយ ។ គ្រានោះ កម្រងផ្កា

មណ្ឌារវព្រឹក្សជារបស់ទិព្វនៅឋានសួគ៌ទេវលោក ដែលទេវតាទាំងឡាយបណ្ដាលឲ្យធ្លាក់ចុះមកបូជា ដេរដាសពាសពេញទាំងនគរកុសិនារា ដោយប្រមាណកំពស់ត្រឹមជានុមណ្ឌល ៗ លំដាប់នោះទេវតានឹងមល្លក្សត្រទាំងឡាយព្រមគ្នាធ្វើសក្ការបូជាព្រះពុទ្ធសរីរៈដោយរបាំកំច្រៀងប្រគំដូរ្យ-តន្ត្រី និងមាលាសុគន្ធជាតិទាំងជារបស់ទិព្វនិងរបស់មនុស្សគគ្រឹកគគ្រេងជាមហាកោលាហល និមន្តព្រះសរីរៈទៅខាងឧត្តរទិសនៃព្រះនគរ ចូលមកខាងព្រះនគរដោយឧត្តរទិស កាត់ត្រង់ពាក់កណ្ដាលព្រះនគរតាមទ្វារខាងបុព្វទិសទៅប្រតិស្ឋានធា មកុដពន្ធនចេតិយ ជាមណ្ឌលស្ថានដែលមល្លក្សត្រទ្រទ្រង់នូវគ្រឿងប្រដាប់ប្រតិស្ឋានព្រះពុទ្ធសរីរៈព្រមទាំងសក្ការបូជាដ៏ឧឡារិក គគ្រឹកគគ្រេងដែលគេតែងសន្មតថាជាមណ្ឌលដ៏-ឧត្តមក្នុងនគរនោះ សម័យនោះ មល្លក្សត្រទាំងឡាយមានបំណងចង់ជ្រាបការប្រតិបត្តិព្រះពុទ្ធសរីរៈឲ្យត្រូវតាមពុទ្ធាធិប្បាយ ទើបទូលសួរព្រះមហាអានន្ទត្ថេរ ៗ លោកក៏សំដែងពុទ្ធានុម័តិ ដែលឲ្យប្រតិបត្តិក្នុងព្រះសរីរៈនៃព្រះចៅចក្រពត្តិរាជតាមន័យ ដែលលោកបានស្ដាប់មកក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថ្វាយឲ្យមល្លក្សត្របានជ្រាបសព្វគ្រប់ការ ៗ

មល្លក្សត្រទាំងឡាយ ក៏ទ្រង់ប្រតិបត្តិតាមពុទ្ធាធិប្បាយនោះ គឺរុំ

ព្រះសរីរៈដោយសំពត់ថ្មី ព្រាប់ដោយសំឡីហើយរុំដោយសំពត់ថ្មី ព្រាប់ដោយសំឡីទៀត ធ្វើបែបនេះដកបត្រប់ ៥០០ ជាន់ ស្រេចហើយក៏និមន្តព្រះសរីរៈទៅប្រតិស្ឋានលើកនដែកដែលពេញដោយប្រេង បិទដោយគំរបដែក ធ្វើចិតកាធារដោយឈើក្រអូប ហើយដំកល់ព្រះសរីរៈលើចិតកាធារនោះប្រុងប្រៀបនឹងថ្វាយព្រះភ្លើង ។

គ្រានោះ មល្លបាមោក្ខ ៤ អង្គ ស្រង់ទឹកជម្រះកាយបរិសុទ្ធស្អាត បាតស្លៀកដណ្តប់ដោយសំពត់ថ្មី នាំភ្លើងជាប្រក្រតីចូលទៅកាន់ចិតកាធារទាំង ៤ ទិស តែមិនអាចដុតភ្លើងឲ្យឆេះក្នុងចិតកាធារនោះបានឡើយមល្លក្សត្រទាំងឡាយសង្ស័យថា ក្រែងទំនាស់ដោយឥទ្ធានុភាពរបស់ទេវតា ទើបទូលសួរព្រះអនុរុទ្ធត្ថេរ ៗ លោកសំដែងហេតុថា "ទេវតាទាំងឡាយមានបំណងនឹងរង់ចាំឲ្យព្រះមហាកស្សបត្ថេរនិមន្តមកថ្វាយបង្គំព្រះបាទព្រះមានព្រះភាគដោយសិរសាសិន ទើបថ្វាយព្រះភ្លើងបាន ។

សម័យនោះ ព្រះមហាកស្សបត្ថេរ លោកពុំទាន់និមន្តមកដល់មកុដ-ពន្ធនចេតិយនៅឡើយ លោកកំពុងធ្វើដំណើរតាមផ្លូវមកពីនគរបាវ៉ាជាមួយនឹងភិក្ខុ ៥០០ រូបហើយចូលមកឈប់សម្រាកក្រោមម្លប់ព្រឹក្សមួយដើម បានឃើញអាជីវកម្នាក់កាន់ផ្កាមណ្ឌារវព្រឹក្សដើរមកពីទិសឆ្ងាយ បំណងនឹង

ទៅស្រុកបាវា ព្រះមហាកស្សបត្ថេរក៏សួរថា "អ្នកបានជ្រាបអំពីដំណើរព្រះសាស្ដារបស់យើងខ្លះដែរឬ ? " អាជីវកប្រាប់ថា "យើងបានជ្រាបសមណគោតមបរិនិព្វាន ៧ ថ្ងៃនឹងថ្ងៃនេះហើយ ផ្កាមណ្ឌារព្រឹក្សនេះយើងយកមកអំពីទីដែលសមណគោតមបរិនិព្វាននោះឯង"។ យោគេតវែកក-ត ព្រោះនោះព្រះភិក្ខុខ្លះដែលមានរាគៈមិនទាន់ទៅប្រាសចាកសន្ដាន ក៏លើកហត្ថទាំងពីរឡើងយំសោក ខ្សឹកខ្សួលបំរះនេះទៀលអាឡោះអាល័យព្រះមានព្រះភាគ ចំណែកភិក្ខុដែលមានរាគៈទៅប្រាសហើយ ក៏មានសតិសម្បជញ្ញៈអត់សង្កត់ដោយធម្មសង្វេគ ។ តេន ខោ បន សមយេន សម័យនោះឯងមានបព្វជិតអ្នកបួសខាងចាស់១រូបឈ្មោះសុភទ្ទៈ បានដើរតាមព្រះថេរៈមកនៅក្នុងចំណោមបរិស័ទនោះដែរ ស្រែកហាមភិក្ខុទាំងឡាយថា៖"អលំ អាវុសោ ម្នាលអាវុសោឈប់ទៅ លោកទាំងឡាយកុំសោយសោកអាឡោះអាល័យដល់សមណៈនោះឡើយ សុម្មុត្តា មយំ យើងទាំងឡាយបានផុតស្រឡះដោយល្អហើយអំពីសមណៈនោះ, សមណៈនេះតែងប្រដៅថា របស់នេះគួរ របស់នេះមិនគួរ យើងខ្លាចក្រែងក៏ព្រមធ្វើតាមដោយសេចក្ដីលំបាកខ្លាំងណាស់ ឥឡូវនេះ យើងចង់ធ្វើអ្វីក៏បានយើងមិនចង់ធ្វើអ្វីក៏បានតាមចិត្ត ឥតចាំបាច់កោតក្រែងបង្គាប់បញ្ជាអំពីនរ-

ណាឡើយ ។ ឯសត្តាហបរិនិព្វុតេ នូវព្រះបរមសាស្ដាទើបតែបរិនិព្វាន
ទៅមិនយូរប៉ុន្មានបាន ៧ ថ្ងៃប៉ុណ្ណោះ មានអលជ្ជីបាបជនហ៊ានពោលពាក្យ
បម្រងបម្រាស់ត្មះតិះដៀលក្នុងធម្មវិន័យ ដោយឥតមានគោរពក្រែងសោះ ។
ចំណែកព្រះមហាកស្សបត្ថេរបានស្ដាប់ហើយ ក៏លើកជាអធិករណ៍បំរុង
នឹងធ្វើនិគ្គហកម្ម តែដោយយល់ថា នៅមិនគួរ ទើបមានថេរវាចហាម
ភិក្ខុសង្ឃដោយផ្លូវធម៌ ហើយនាំភិក្ខុសង្ឃសញ្ចរទៅដើម្បីថ្វាយព្រះយុគល
បាទនៃព្រះសម្មាសម្ពុទ្ធ ដែលប្រតិស្ឋាននៅមកុដពន្ធនចេតិយនោះ ។
បក្ខាកេ បន មល្លបាមោក្ខា ចំណែកមល្លក្សត្រទាំងឡាយ និមន្តព្រះ
សរីរៈទៅប្រតិស្ឋាននៅលើចិតកាធារហើយ ទើបមល្លបាមោក្ខ ៤ អង្គស្រង់ទឹក
ជម្រះកាយទ្រទ្រង់នូវភូសាថ្មី នាំភ្លើងចូលទៅដុតចិតកាធារ មិនអាចឆួល
ឲ្យឆេះនូវចិតកាធារនោះបាន ដោយទេវតាទាំងឡាយមានបំណងថាឲ្យ
ព្រះមហាកស្សបត្ថេរ ដែលកំពុងនិមន្តមកតាមមាគ៌ាចូលថ្វាយបង្គំព្រះយុគ
លបាទសិន ទើបបណ្ដាលដោយទេវឫទ្ធិវិស័យ ហាមមល្លបាមោក្ខដោយ
ប្រការដូច្នេះ ។ លុះមល្លក្សត្របានជ្រាបដំណើរការណ៍អំពីសំណាក់ព្រះ
អនុរុទ្ធត្ថេរហើយ ទើបផ្អាក់ការណ៍នោះតាមទេវាធិប្បាយ ។

កាលព្រះមហាកស្សបត្ថេរ នាំព្រះភិក្ខុសង្ឃ មកដល់មន្តលស្ថាន

មកុដពន្ធនចេតិយហើយ ក៏នាំមនុស្សចូលទៅជិតចិតកាធារ ធ្វើនូវបង្រ្គួលបីរ ទៀងស្មាម្ខាង លើកកំបង់ផ្ទង់អញ្ជលីប្រណម្យហត្ថមស្តកថ្វាយបង្គំធ្វើ ប្រទក្សិណចិតកាធារ ៣ ជុំហើយ បាទតោ វិវរិត្វា បើកពីខាងព្រះបាទ ថ្វាយបង្គំព្រះបាទទាំងគូនៃព្រះមានព្រះភាគដោយសិរសានៃខ្លួន សម្រេច ដោយកម្លាំងអធិដ្ឋានដ៏ងឥទ្ធិវិស័យជាអចិន្ត្យមិនគួរសញ្ជឹងរំពឹងគិត ។ តានិ តោ បញ្ចភិក្ខុសតានិ សូម្បីភិក្ខុទាំង ៥០០ អង្គនោះ ក៏ប្រទនូវ បីរទៀងស្មាម្ខាងធ្វើប្រទក្សិណចិតកាធារ ៣ ជុំហើយថ្វាយបង្គំព្រះមាន ព្រះភាគដោយសិរសារបស់ខ្លួនរៀងៗខ្លួន ។

វេទិតេ បទាយស្មា មហាកស្សបេ កាលព្រះមហាកស្សបត្ថេរ ដ៏មានអាយុព្រមទាំងភិក្ខុ ៥០០ អង្គថ្វាយបង្គំហើយ ចិតកាធារក៏រុងរឿង ព្រោងព្រាតឡើងឯង សំដែងបាដិហារិយ៍ឲ្យប្រាកដ (ព្រះអដ្ឋកថាចារ្យ សំដែងថាភ្លើងទិព្វកើតឡើងដោយអំណាចនៃទេវតានុភាព ។ ឈាយ មានស្ស តោ បន ក៏កាលភ្លើងកំពុងឆាបឆេះនូវចិតកាធារព្រះឆវិខាងក្រៅ ព្រះចម្មះខាងក្នុង នហារូ និងសរសៃតូចធំជាដើមក៏រលត់រលាយទៅ ដោយកម្លាំងភ្លើង ដោយឥតមានសូម្បីតែផេះប្រាកដឡើយ ដូចជា សប្បិឬប្រេងដែលត្រូវភ្លើងឆេះហើយដូរធ្លាះដែរ តែចំណែកព្រះសរីរៈ

គឺព្រះអង្គ, ព្រះកេសា ព្រះលោមា, ព្រះនខា, ព្រះទន្តា, សល់នៅឥតមានខេះឡើយ ព្រមទាំងសំពត់ ១ គូ សល់នៅជាប្រក្រតីសម្រាប់រុំខ្ចប់ព្រះសារីរិកធាតុ ក្រៅអំពីនេះ ភ្លើងឆេះទាំងអស់ឥត-មានសេសសល់ឡើយ ។ ទឌ្ឍេ ខោ បន ភគវតោ សរីរេ កាលព្រះសរីរៈនៃព្រះមានព្រះភាគសម្រេចឈាបនកិច្ចហើយ ឧទកធារាក៏បន្ទុំទឹកធ្លាក់ចុះអំពីកណ្ដាលអាកាសមករំលត់ភ្លើងលើចិតកាធារជលោទកក៏ផុសផុសចេញមកពីសាលព្រឹក្សនោះរំលត់ភ្លើង (ភ្លើង) លើចិតកាធារនៃព្រះមានព្រះភាគ សូម្បីតែមល្លក្សត្រទាំងឡាយក៏នាំមកនូវសព្វសុគន្ធរំលត់ (ភ្លើង) នាចិតកាធារនៃព្រះមានព្រះភាគដែរ លុះស្រេចហើយទើបនិមន្តព្រះសារីរិកធាតុទៅប្រតិស្ឋាន នៅសណ្ឋាគារសាលាក្នុងក្រុងកុសិនារា ធ្វើសត្តិបញ្ជរជុំវិញសណ្ឋាគារដ្ឋាន មានទាហានឈរកាន់ធ្នូ-ពទ្ធជាកំផែងព័ទ្ធខាងក្នុង ដោយបំណងនឹងមិនឲ្យក្សត្រសាមន្តដទៃទេស លើកព្យុហ៍សេនាព្យុហ៍ពលមកដណ្ដើមព្រះសារីរិកធាតុបានប្រគំធ្វើសក្ការបូជារាំច្រៀងសង្គីតប្រគំដូរ្យតន្ត្រី និងបុប្ផមាលាសុគន្ធជាតិជាអនេកប្រការ លេងសាធុការឡើងគគ្រឹកគគ្រេងគឹកកងរំពងអស់កាល ៧ ថ្ងៃជាកំណត់ ។

## ការចែកព្រះសារីរិកធាតុ

អស្ចារ្យ ទៅ គ្រានោះព្រះបាទមគធាធិបតី វេទេហិបុត្រអជាតសត្រូវ គ្រប់គ្រងសម្បត្តិឯករាជ្យ ក្នុងរាជគ្រឹះមហានគរ, ក្សត្រលិច្ឆវីដែលជាវង្សត្រកូលក្នុងនគរវេសាលី, ក្សត្រសក្យរាជព្រះញាតិវង្សគ្រងកបិលពស្តុរាជធានី , ថូលីក្សត្រជាអធិបតី ក្នុងអល្លកប្បនគរ , កោលិយក្សត្រ ក្នុងនគររាមគ្រាម, មហាព្រាហ្មណ៍ជាម្ចាស់ស្រុកវេដ្ឋទីបកនគរ ព្រមទាំងមល្លក្សត្រដែលគ្រងនគរបាវា ក្សត្រទាំង ៦ នគររួមនឹងមហាព្រាហ្មណ៍ផងជា ៧ បានជ្រាបពត៌មានថា: ព្រះមានព្រះភាគទ្រង់ស្តេចរំលត់ខន្ធចូលកាន់បរិនិព្វាន ក្នុងសាលវនោទ្យានកុសិនារាជធានី ។ ក្សត្រទាំង ៦ ព្រះនគរក៏បញ្ជូនរាជទូតឲ្យនាំរាជសាសន៍មកថ្វាយមល្លក្សត្រក្នុងក្រុងកុសិនារា ។ សេចក្តីក្នុងព្រះរាជសាសន៍នោះថា ភគវាបិ ខត្តិយោ មយម្បិ ខត្តិយា ព្រះមានព្រះភាគព្រះអង្គជាព្រះបរមក្សត្រខត្តិយវង្ស យើងទាំងឡាយក៏ជាខត្តិយជាតិដ៏ឧត្តម យើងទាំងឡាយគួរនឹងបានដោយជាចំណែក នូវចំណែកនៃព្រះសារីរិកធាតុនៃព្រះមានព្រះភាគជាម្ចាស់ យើងទាំងឡាយនឹងបានដំកល់ទុកក្នុងព្រះស្តូបធ្វើសក្ការបូជាដ៏ឧឡារិក ។ ចំណែកព្រាហ្មណ៍ជាវង្ស

ក្នុងវេឡុទ្វារកនគរ    ក៏បញ្ជូនព្រាហ្មណ៍ទូតឲ្យនាំព្រាហ្មណ៍សាសន៍ទៅ
គាល់មល្លក្សត្រ ។ សេចក្ដីក្នុងព្រាហ្មណ៍សាសន៍នោះថា: ភគវាបិខត្តិ-
យោ ព្រះមានព្រះភាគជាក្សត្រវិសុទ្ធិវង្ស ខ្ញុំព្រះអង្គក៏ជាព្រាហ្មណ៍ជាតិ
ដ៏ឧត្តុង្គឧត្តមមហាសាល គួរនឹងបានទទួលព្រះរាជទាននូវចំណែកនៃព្រះ
សារីរិកធាតុនៃព្រះគោតមបរមសាស្ដា ខ្ញុំ: នឹងបានប្រតិស្ឋានក្នុងព្រះស្ដូប
ដើម្បីនឹងបានធ្វើសក្ការបូជាតាមកម្លាំងទ្រព្យនឹង ចលាចលសត្វា ។ គេ
ទូតា   រាជទូតនឹងព្រាហ្មណ៍ទាំងឡាយនោះក៏នាំគ្នាធ្វើដំណើរទៅកាន់
នគរកុសិនារា   បានចូលទៅគាល់មល្លក្សត្រ   ថ្វាយសាសន៍តាម
បញ្ជាហើយក៏តាំងនៅជាពួក ៗ ព្រមដោយព្យូហ៍ពល ។ អថ ខោ
លំដាប់នោះមល្លក្សត្រទាំងឡាយ   មានព្រះរាជឱង្ការទៅកាន់ទូតានុទូត
ទាំងឡាយនោះដោយសុរវេចនៈថា ភគវា អម្ហាកំ គាមខេត្តេ បរិនិព្វុតោ
ព្រះមានព្រះភាគព្រះអង្គបរិនិព្វាន   ក្នុងគាមខេត្តរបស់យើងទាំងឡាយ
ន មយំ ទស្សាម   យើងទាំងឡាយនឹងមិនព្រមឲ្យនូវចំណែកនៃព្រះ
សារីរិកធាតុដល់ស្ដេចទាំងឡាយនោះឡើយ ។ កាលទូតានុទូតនិករមក
ទូលសុំចំណែកព្រះសារីរិកធាតុនោះ   មល្លក្សត្រទាំងឡាយមិនពោល
តបដោយពាក្យទន់ភ្លន់ទនល់ទោនឡើយ ។ ចំណែកទូតានុទូតទាំងឡាយ

នោះក៏មិនព្រមថយចេញ នាំគ្នានៅរង់ចាំតស៊ូដោយតាំងចិត្តថា នឹងសូមយកនូវចំណែកនៃព្រះសារីរិកធាតុឲ្យបាន ។ ការណ៍នេះក៏ទៅជាកើតទាំងត្រៀមធ្វើសង្គ្រាមច្បាំងគ្នា ដើម្បីដណ្តើមយកនូវចំណែកនៃព្រះសារីរិកធាតុ ។

គ្រានោះ ទោណព្រាហ្មណ៍ជាអ្នកមានបញ្ញាឈ្លៀវឆ្លាស់គិតថា ការដែលមហាក្សត្រមិនព្រមចែកនូវចំណែកព្រះសារីរិកធាតុ ដោយពាក្យសុំពោលយ៉ាងនេះមិនគួរទេឡើយ ហេតុតែនេះនឹងនាំឲ្យកើតសង្គ្រាមធំ ដោយសារតែព្រះសារីរិកធាតុ ដូច្នេះគួរតែគ្នាអញ្ជើញសំដែងគុណខន្តិ នឹងគុណនៃសេចក្តីព្រមព្រៀងគ្នានៃមហាក្សត្រទាំងនេះ ដើម្បីញ៉ាំងអធិករណ៍នេះឲ្យស្ងប់ដោយសាមគ្គីធម៌ ។ ទោណព្រាហ្មណ៍គិតដូច្នោះហើយ ទើបពោលព្រះគាថានេះថា សុណន្តុ ភោន្តោ មម ឯកវាក្យំ ដូច្នេះជាដើម សេចក្តីថា បពិត្រគណាធិករដ៏ចម្រើនទាំងឡាយ សូមទ្រង់ស្តាប់ឯកវាចារបស់ខ្ញុំក្នុងគ្រានេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូ ព្រះអង្គជាទីពឹងនៃយើងទាំងឡាយ ព្រះអង្គជាខន្តិវាទ ពោលសរសើរសេចក្តីអត់ធន់ចំពោះពាហិរទុក្ខនឹងកម្លាំងកិលេស, ការដែលប្រារព្ធនូវចំណែកនៃព្រះសារីរិកធាតុ នៃព្រះអង្គជាឧត្តមគតិឲ្យជាដើមហេតុហើយ

បន្តិចកើតការតស៊ូដោយសស្ត្រាវុធជាសង្គ្រាមឡើង ជាការមិនល្អឡើយ បពិត្រព្រះអង្គដ៏ចំរើនអើយ គួរយើងទាំងឡាយព្រមព្រៀងរីករាយរកគ្នាដើម្បីសេចក្ដីក្សេមក្សាន្ត ចែកព្រះសារីរិកធាតុជាចំណែកឲ្យបានស្មើគ្នាគ្រប់នគរទៅចុះ ហេតុ វិសាសុ ថូបា សូមឲ្យព្រះស្តូបបានបញ្ចុះព្រះសារីរិកធាតុនៅគ្រប់ទិសដើម្បីឲ្យបានសំរេចប្រយោជន៍សុខដល់សត្វនិករទាំងឡាយអស់កាលយូរ ពហូ ជនា ចក្ខុមតោ បសន្នា ព្រោះជនទាំងឡាយដែលមានសេចក្ដីជ្រះថ្លា ចំពោះព្រះអង្គដែលមានញាណចក្ខុនោះមានច្រើនណាស់ ។ ទោណព្រាហ្មណ៍ពោលពាក្យសំដែងអំពីខន្តិភាពនិងសាមគ្គីធម៌ដោយប្រការដូច្នេះ ។

លំដាប់នោះ ក្សត្រិយ៍និងព្រាហ្មណ៍ទាំង ៨ នគរ បានស្ដាប់មធុរ-កថាហើយ ក៏ទ្រង់អនុម័តយល់ព្រមសព្វព្រះរាជហឫទ័យតាមសាមគ្គីធម៌ ព្រមប្រគល់ធុរកិច្ចនោះ ឲ្យទោណព្រាហ្មណ៍ជាអធិបតីក្នុងការចែកនូវចំណែកព្រះសារីរិកធាតុនៃព្រះបរមគ្រូ ។ ឯវំ ភោតិ ខោ ចំណែកទោណព្រាហ្មណ៍បានទទួលព្រះរាជបញ្ជាហើយ ក៏កាន់តុម្ពៈជាវិការនៃមាសថ្លឹងនូវព្រះបរមធាតុជាភាគស្មើៗគ្នា ថ្វាយក្សត្រិយ៍និងមហាព្រាហ្មណ៍ទាំង ៩ នគរស្រេចហើយ ទើបទទួលសូមតុម្ពៈដែលជារបស់

ត្រូវដល់ទេតិយស្ថានៗ ក្សត្រទាំងមហាព្រាហ្មណ៍ក៏អនុញ្ញាតព្រះរាជទាន ។

អស្សោកសុំ ទោ មៅរិយក្សត្រ ជាវង្សក្រុងបិប្ផលិវ័ន បាន ទ្រង់ជ្រាបថា ព្រះមានព្រះភាគស្តេចរំលត់ខន្ធចូលបរិនិព្វានក្នុងក្រុងកុសិនារា ហើយបញ្ជូនទូតមកសូមចំណែកនៃព្រះធាតុ ។ ឯចំណែកមល្លក្សត្រទ្រង់ត្រាស់តបទៅកាន់ទូតនោះថា នត្ថិ សរីរភាគោ ចំណែកសារីរិកធាតុសល់នៅនេះគ្មានទេ យើងបានចែកជាចំណែកស្រេចទៅហើយ លោកចូរនាំយកនូវព្រះអង្គារទៅបញ្ចុះក្នុងស្តូបស្ថានធ្វើសក្ការបូជាចុះ ។

## ទេសនានិដ្ឋានកថា

ឯត្តាវតា កតវេតា សុនិត្តុកស្ស តាទិតា

។ល។

សិទ្ធំ បរប្បាត្ត សម្មាវ ទុក្ករមោក្ខំ យថិច្ឆិតំ

កថាដែលសំដែងអំពីប្រវត្តិ របស់ព្រះមានព្រះភាគ ដែលជាអគ្គបុគ្គលទ្រង់នូវគាទិគុណជាដួងចក្ខុឯកក្នុងលោក សំដែងប្រាប់នូវផ្លូវនៃព្រះនិព្វានចាប់ដើមតាំងពីព្រះអង្គស្តេចចូលបរិនិព្វាន ដរាបដល់ថ្វាយព្រះភ្លើង ហើយក្សត្រព្រាហ្មណ៍ជាបណ្ឌិត ដែលជ្រះថ្លាបានចិត្ត

ព្រះសារីរិកធាតុទៅប្រតិស្ឋានក្នុងព្រះស្តូបទុកក្នុងប្រទេស និងកាណាខេត្ត
នោះៗ រហូតដល់ទីបំផុត គឺសំដែងទៅតាមវារៈព្រះបាលី ជាកថាគួរឲ្យកើត
សេចក្តីសង្វេគនិងសេចក្តីជ្រះថ្លាដល់សាធុជនទាំងឡាយ ដែលបានអាន
បានស្តាប់ ព្រមទាំងបានសំដែងអំពីហេតុផលសក្តុបការសម្បទាទាំង ៣
តាមសមគួរ ។ សូមសាធុជនជាបណ្ឌិត គប្បីរលឹករឿយ ៗ
ដល់ព្រះសម្មាសម្ពុទ្ធជាធំលើនរៈប្រកបដោយសម្បទាគុណ ដ៏អស្ចារ្យ
ដូចបានពណ៌នាមកប៉ុណ្ណេះនេះ ហាក់ជាពុទ្ធានុស្សតិភាវនាមួយអនុត្ត-
រិយកុសល ដើម្បីញ៉ាំងបសាទសទ្ធាឲ្យផុះដាលលូតលាស់ចម្រើនក្នុង
សន្តាន ហើយគិតដល់ធម៌ដែលព្រះទ្រង់ញាណបានសំដែងទុកដោយល្អ
ជាធម្មានុស្សតិតាមលំដាប់រលឹកដល់សង្ឃសាវក ដែលលោកទ្រទ្រង់
ដោយប្រពៃនូវធម៌ដោយអភិសម័យ ហាក់ជាសង្ឃានុស្សតិភាវនា ។
ការរលឹកដល់គុណនៃព្រះរតនៈទាំង ៣ ប្រការដូច្នេះនេះ ជាបុណ្យ
កុសលពលីឲ្យតាំងនៅជាស្ពានក្នុងសរណគមន៍ នាំឲ្យបានជ្រាប
ច្បាស់ក្នុងធម៌វិន័យ នៃព្រះតថាគតបណ្តុះសេចក្តីជ្រះថ្លាឲ្យមាំក្នុងព្រះ
រតនត្រ័យ អាចបានទទួលសេចក្តីសុខសួស្តីសិរីសុភមង្គលសំរេច
ផលតាមបំណងគ្រប់ប្រការ ។ ទេវតានិងមនុស្សទាំងឡាយណា

ដែលមានសេចក្ដីជ្រះថ្លាក្នុងគុណព្រះត្រៃយរ័ត្ន ជ្រះថ្លាប្រាកដក្នុងចិត្តផុត ប្រែប្រួលត្រូវដល់ផលវិបាក សូមទេព្ដាគឺមនុស្សទាំងឡាយនោះ ចូរបន្ទុះនូវវិសេសប្រយោជន៍សមតាមសេចក្ដីប្រាថ្នា ដែលជាធម៌ប្រាសចាកទុក្ខទោសភ័យចៃក្ដីក្នុងវដ្ដសង្សារ សម្រេចដល់អមតធម៌ដោយប្រពៃនៃខ្លួនគ្រប់ ១ រូបទៅហោង ។

**ចប់ពុទ្ធប្បទក្តិសន្តិគេនិធាន**
**តែប៉ុណ្ណោះ**

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សយ សិលា

វិច្ឆិកា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដាវី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ឺស និងលោកម្តាយ ឌិន សៅខុន

សូមអរគុណ

ខ្ចៅ ឃុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

**មានជាបដុំ និង ជាបរាយ**

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារចំរើនរតន៍"

# 136Eo វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ **012 706 581**

**097 905 00 55**

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។